# អ្នកនាំសារ

# The Messenger

35

ខែមិថុនា ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៏កាតូលិកប៉ុណ្ណោះ






កំណើននៃអំពើរំលោភសេពសន្ថវៈ

ទំព័រ ៨



អាហារូបករណ៍ឆ្នាំ ២០០៦-២០០៧

ទំព័រ ១១

ទំនាក់ទំនងល្អ តើវាអាស្រ័យលើកត្តាអ្វីខ្លះ?

ទំព័រ ១២

# សន្ទរកេ្មងៗ

## តើលោកប៉ូលជានរណា ?



Photo: DR

លោកជាគ្រីស្តទូតដែលព្រះអម្ចាស់យេស៊ូបានជ្រើសរើសក្រោយពេលដែលព្រះអង្គសោយទិវង្គត ហើយព្រះជាម្ចាស់ប្រោសឱ្យមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង។ លោកជាជនជាតិយូដា កើតនៅក្រុងតាសុស ក្នុងស្រុកស៊ីលីស៊ី។ ប៉ុន្តែលោករស់នៅក្នុងក្រុងយេរូសាឡឹមតាំងពីកុមារ ហើយបានទទួលការអប់រំតាមធម៌វិន័យនៃបុព្វបុរសយូដាយ៉ាងតឹងរ៉ឹងបំផុតពីសំណាក់លោកកាម៉ាលីអែល។ ឈ្មោះដើមលោកគឺ "សូល"។ លោកសូលបានទទួលមុខងារពីក្រុមមហាបូជាចារ្យដើម្បីកំចាត់កំចាយ គំរាមគំហែង និងសម្លាប់ សាវ័កគ្រប់ទីកន្លែងនៅក្រុងយេរូសាឡឹម និងក្រុងផ្សេងៗទៀត។

**តើលោកប៉ូលប្រែចិត្តគំនិតនៅពេលណា ?**

លោកសូល "ប៉ូល" បានសុំលិខិតអនុញ្ញាតចូលក្នុងសាលាប្រជុំនានានៅក្នុងក្រុងដាម៉ាស។ ពេលគាត់ធ្វើដំណើរជិតដល់ក្រុងដាម៉ាស ស្រាប់តែមានពន្លឺមួយចាំងពីលើមេឃជុំវិញគាត់ ធ្វើឱ្យគាត់ដួល ហើយឮសម្លេងមួយពោលមកគាត់ថា : "សូល! ហេតុដូចម្តេចបានជាអ្នកបៀតបៀនខ្ញុំ ?" លោកតបវិញថា : "តើលោកជានរណា ?" សម្លេងនោះតបថា : "ខ្ញុំជាយេស៊ូដែលអ្នកកំពុងតែបៀតបៀន"។ បន្ទាប់មកព្រះយេស៊ូចាត់គាត់ឱ្យចូលក្រុងដាម៉ាសដើម្បីជួបក្រុមសាវ័កនៅទីនោះ។ ពេលនោះភ្នែករបស់គាត់ពុំអាចមើលឃើញឡើយ។ នៅក្រុងដាម៉ាស លោកអាណាញ៉ាស ជាសាវ័កម្នាក់ដែលជឿព្រះយេស៊ូបានប្រោសភ្នែកលោកឱ្យអាចមើលឃើញវិញ។ លោកប៉ូលចាប់ផ្តើមជឿព្រះយេស៊ូ និងបានទៅប្រកាសដំណឹងល្អនៅគ្រប់ច្រកល្ហករហូតត្រូវគេសម្លាប់ប្រហែលនៅឆ្នាំ៦២ នៅទីក្រុងរ៉ូម ដោយកាត់ក្បាល។

លី សុវណ្ណា

# អធិប្បាយព្រះបន្ទូល

## ថ្ងៃទី ១១ មិថុនា បុណ្យលើកតម្កើងព្រះត្រៃឯក

### "ចូរធ្វើពិធីជ្រមុជទឹកឱ្យគេ ដើម្បីឱ្យគេរួមជាមួយព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ"

(ម៉ាថាយ ២៨,១៦-២០)

យើងជាគ្រីស្តបរិស័ទ ផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូ ជាព្រះគ្រីស្ត គឺយើងរួមស្លាប់រស់ជាមួយព្រះអង្គទៅជាបុត្រធីតារបស់ព្រះបិតា ព្រោះយើងបានទទួលព្រះវិញ្ញាណ ជាព្រះជន្មផ្ទាល់របស់ព្រះអង្គ។ យើងមានបទពិសោធន៍ខ្លះអំពីការណ៍ដ៏អស្ចារ្យនៃព្រះត្រៃឯក គឺព្រះជាម្ចាស់មានតែមួយព្រះអង្គគត់ តែជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដាច់ពីគ្នា តែរួមគ្នាជាព្រះអម្ចាស់តែមួយពេលយើងអធិដ្ឋាន។ នៅពេលនោះយើងរួមចិត្តគំនិតយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ ដែលនាំយើងទៅកាន់ព្រះបិតា ពេលនោះព្រះវិញ្ញាណបន្លឺព្រះសូរសៀងថា : "អប្បា ឪ ប៉ា"។ ពេលយើងអធិដ្ឋាន យើងមានទំនាក់ទំនងជាមួយព្រះត្រៃឯកយ៉ាងស្និទ្ធស្នាលបំផុត។ នៅពេលយើងគូសសញ្ញាឈើឆ្កាងលើខ្លួនយើង យើងក៏នឹកថា ខ្លួនគឺជាបុត្រធីតារបស់ព្រះបិតា ព្រោះយើងរួមជាមួយព្រះយេស៊ូជាព្រះបុត្រា។ ព្រះអង្គប្រទានព្រះវិញ្ញាណ



ដែលជាព្រះជន្មផ្ទាល់របស់ព្រះអង្គ។ ជំនឿចំពោះព្រះត្រៃឯកមិនមែនជាទ្រឹស្តីពិបាកយល់ទេ គឺជាការប្រកាសសរុបជំនឿរបស់យើង និងសម្តែងអំពីព្រះហឫទ័យមេត្តាករុណា ដ៏លើសលប់របស់ព្រះជាម្ចាស់ ដែលចែករំលែកព្រះជន្មផ្ទាល់របស់ព្រះអង្គឱ្យអ្នកជឿ។

## ថ្ងៃទី ១៨ មិថុនា បុណ្យលើកតម្កើងព្រះកាយ និងព្រះលោហិត

### "នេះជារូបកាយរបស់ខ្ញុំ... នេះជាលោហិតរបស់ខ្ញុំ ដែលត្រូវគេបង្ហូរ"

(ម៉ាកុស ១៤,១២-១៦. ២២-២៦)

លោកយេស៊ូមិនចង់ស្លាប់ទេ លោកលាក់ការណ៍ មិនឱ្យអ្នកស្អប់លោកដឹងថា លោកទៅជប់លៀង ក្នុងឱកាសបុណ្យចម្លង នៅកន្លែងណាឡើយ។ នៅពេលជប់លៀង លោកធ្វើកាយវិការតាមទំនៀមទម្លាប់មេក្រុម ឬមេគ្រួសារនៃជនជាតិយូដា (ក្រុមសាវ័កជាគ្រួសាររបស់ព្រះអង្គ)។ នៅពេលចាប់ផ្តើមជប់លៀង លោកអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រោសប្រណីជនជាតិអ៊ីស្រាអែល តាំងពីដើមរៀងមករួចទ្រង់ក៏កាច់នំបុ័ងបែងចែកឱ្យក្រុមសាវ័កបរិភោគ។ នៅពេលចុងក្រោយ លោកធ្វើតាមរបៀបនៃមេគ្រួសារដដែល គឺលោកយកពែងស្រាទី៤ អរព្រះគុណព្រះជាម្ចាស់ និងចែកឱ្យគេបរិភោគដែរ។ ប៉ុន្តែលោកមានប្រសាសន៍ម្យ៉ាង ដែលដូរអត្ថន័យដើមនៃកាយវិការទាំងពីរនោះថា : "នេះជារូបកាយរបស់ខ្ញុំ... នេះជាលោហិតដែលត្រូវគេបង្ហូរសម្រាប់មនុស្សទាំងអស់"។ លោកយេស៊ូធ្វើកាយវិការនេះ ទុកជាប្រផ្នូលអំពីលោកត្រូវគេចាប់យកទៅសម្លាប់ និងបង្ហូរឈាម តែលោកត្រៀមខ្លួនទុកជាមុនដោយបូជា



ជីវិតថ្វាយព្រះបិតា ទុកជាសក្ការៈបូជា ដោយសេចក្តីស្រលាញ់យ៉ាងអស្ចារ្យក្នុងនាមលោកជាតំណាងមនុស្សទាំងអស់។ ហេតុនេះហើយបានជាលោកចងសម្ពន្ធមេត្រី គឺធ្វើឱ្យមនុស្សលោកជាប់ចំណងជាមួយព្រះបិតា ក្នុងនាមយើងទាំងអស់គ្នា។ នៅពេលយើងទទួលនំបុ័ងក្នុងអភិបូជា យើងសុខចិត្តរួមជាមួយព្រះយេស៊ូដែលបូជាព្រះជន្ម យើងក៏សុខចិត្តបូជាជីវិតរួមជាមួយព្រះអង្គដែរ។



## ថ្ងៃទី ២៥ មិថុនា អាទិត្យ ទី១២ រដូវធម្មតាប្រចាំឆ្នាំ

### "លោកគ្រូ! យើងស្លាប់ឥឡូវហើយ!" (ម៉ាកុស ៤,៣៥-៤១)

ពេលបងប្អូនអានអត្ថបទនេះ បងប្អូនត្រូវនឹកអំពីនិមិត្តរូបផ្សេងៗ តាមអរិយធម៌ជនជាតិយូដា គឺរាប់ : សមុទ្រ ទុកជាទីលំនៅពួកមារ។ ត្រើយម្ខាង ជាកន្លែងសាសន៍ដទៃរស់នៅ ទុកជាព្រះសហគមន៍។ ព្រះយេស៊ូផ្ទំលក់ ជានិមិត្តរូបអំពីព្រះអង្គសោយទិវង្គត។ រលកបោកបក់ គឺជាសកម្មភាពរបស់ពួកមារដែលចង់ពន្លិចព្រះសហគមន៍។ល។

នៅក្រោយពេលព្រះយេស៊ូសោយទិវង្គត គេឃើញគ្រីស្តបរិស័ទ ជាពិសេសនៅក្រុមរ៉ូម ជាទីក្រុងលោកម៉ាកុសរស់នៅ ព្រះយេស៊ូដូចជាលះបង់គេចោលហើយ ព្រះអង្គដូចជាធ្វើព្រងើយ ដេកលក់បាត់ហើយ។ តែព្រះវិញ្ញាណព្រះអង្គណែនាំពួកគេ។ សព្វថ្ងៃក្នុងការរស់នៅ ជួនកាលយើងដូចជាទឹកឡើងដល់ច្រមុះ យើងស្មានថា ព្រះយេស៊ូបោះបង់យើងចោល ហើយយើងចង់លះបង់ជំនឿចោលដូចលិចក្នុងសមុទ្រ តែព្រះអង្គនៅតែតាមថែរក្សាអ្នកដែលផ្ញើជីវិតលើព្រះអង្គជានិច្ច។ នៅកម្ពុជា ព្រះសហគមន៍ប្រកាសអំពីដំណឹងល្អ អំពីការសង្គ្រោះរបស់ព្រះយេស៊ូ ដល់ពុទ្ធបរិស័ទ។ ត្រូវរកពាក្យផ្សេងពីពាក្យ ដែលយើងបានរៀនកាលពីកុមារដើម្បីឱ្យបងប្អូនកម្ពុជាស្តាប់បានស្រួល ត្រូវពន្យល់ជំនឿរបស់យើងដោយយករបៀប



ពុទ្ធសាសនាមកនិយាយ។ល។ គ្រីស្តបរិស័ទខ្លះ ភ័យខ្លាច ស្មានថាព្រះសហគមន៍មុខជាវង្វេង ឬបាត់បង់ជំនឿ។ នៅគ្រប់ពេលវេលា និងគ្រប់គ្រោះកាចក្នុងជីវិត ត្រូវនឹកជានិច្ចត្រូវផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូ។ ព្រះអង្គធ្វើដូចជាដេកលក់តែទ្រង់គង់នៅជាមួយព្រះសហគមន៍ជានិច្ច។

## ថ្ងៃទី ០២ កក្កដា អាទិត្យ ទី១៣ រដូវធម្មតាប្រចាំឆ្នាំ

### "នាងគ្រាន់តែដេកលក់... ចូរក្រោកឡើង" (ម៉ាកុស ៥,២១-៤៣)

"ទុក្ខំ អនិច្ចំ អនត្តា"។ មនុស្សយើងគ្រប់ៗរូប មានបទពិសោធន៍ថា យើងតែងតែរងទុក្ខ ត្រូវប្រែប្រួលនិងត្រូវស្លាប់ជាពុំខាន។ ព្រះពុទ្ធរកផ្លូវណែនាំមនុស្សឱ្យជៀសផុតពីទុក្ខ។ ព្រះអង្គទទួលជំនឿតៗ ពីជនជាតិឥណ្ឌាថា វិញ្ញាណក្ខន្ធវិលវល់តាមវាលវដ្តសង្សារដ៏ធំធេងតាមកម្មផល។

អត្ថបទគម្ពីរដំណឹងល្អ ជួយយើង ឱ្យរិះគិតអំពីសេចក្តីស្លាប់ និងអំពីជំនឿ។ កូនលោកនាយកធម្មសាលាមានជំងឺជាទម្ងន់ សូមព្រះយេស៊ូ "សង្គ្រោះ" វាឱ្យរួចពីស្លាប់។ តែកូននោះស្លាប់ហើយ។ ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលថា : "កុំខ្លាចអី! គ្រាន់តែជឿប៉ុណ្ណោះ បានហើយ"។ លោកម៉ាកុសទើបថែង អំពីព្រះយេស៊ូប្រោសស្ត្រី ដែលធ្លាក់ឈាមឱ្យបានជា ព្រះអង្គមានព្រះបន្ទូលទៅកាន់នាងថា : "ជំនឿរបស់នាងបានសង្គ្រោះនាងហើយ"។ តើអ្វីទៅការសង្គ្រោះនោះ? អ្នកនិពន្ធគម្ពីរមិនរៀបរាប់អំពីព្រឹត្តិការណ៍ដូចមានកើតឡើងពិតប្រាកដទេ គឺលោកចង់ពន្យល់អំពីជំនឿរបស់គ្រីស្តបរិស័ទចំពោះព្រះយេស៊ូ។ ព្រះ



អង្គ យាងមកដូរអត្ថន័យនៃសេចក្តីស្លាប់ "នាងគ្រាន់តែដេកលក់ទេតើ" រួចព្រះអង្គចាប់ដៃក្មេង "ឱ្យក្រោកឡើង" ដូចជាព្រះជាម្ចាស់បានប្រោសលោកយេស៊ូក្រោកពីចំណោមមនុស្សស្លាប់ដូច្នោះដែរ។ ចំពោះគ្រីស្តបរិស័ទ យើងជឿថាមនុស្សស្លាប់ទទួលព្រះជន្មថ្មី រួមជាមួយព្រះយេស៊ូដែលទទួលព្រះជន្មថ្មីដ៏រុងរឿងហើយ។ យើងភ័យយើងខ្លាចស្លាប់ដូចគេដូចឯងតែ យើងជឿថាមនុស្សទទួលជីវិតថ្មី រួមជាមួយព្រះយេស៊ូដែលគង់នៅជាមួយព្រះបិតា។

**សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា !**



## សេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់ !

នៅក្នុងខែនេះ អ្នកនាំសារ សូមលើកយកនូវប្រធានបទមួយអំពី : "សេចក្តីស្រលាញ់" ដើម្បីរិះគិតរួមគ្នា។ នាពេលកន្លងទៅ សម្តេចប៉ាបបានសរសេរលិខិតមួយនិយាយអំពីសេចក្តីស្រលាញ់។ លោកបានបញ្ជាក់ថា សេចក្តីស្រលាញ់ចែកចេញជាពីរប្រភេទគឺ : ទីមួយ គឺសេចក្តីស្រលាញ់រវាងបុរសម្នាក់ និងស្ត្រីម្នាក់ ជាក្តីស្រលាញ់ដែលស្វែងរកតែសេចក្តីសុខរបស់មនុស្សផ្ទាល់ខ្លួន។ ទីពីរ គឺសេចក្តីស្រលាញ់ដែលស្វែងរកប្រយោជន៍សម្រាប់អ្នកដទៃ ទោះបីជាអ្នកមិនត្រូវបានគេចូលចិត្ត ឬមិនធ្លាប់ស្គាល់ក៏ដោយ។ ក្នុងចំណុចទាំងពីរខាងលើនេះ តើបងប្អូនធ្លាប់មានបទពិសោធន៍ក្នុងចំនុចណាមួយ ? ការត្រាស់ហៅរបស់ព្រះជាម្ចាស់មានរបៀបផ្សេងៗ និងប្រទានមុខងារឱ្យមនុស្សផ្សេងៗពីគ្នា ដើម្បីប្រកាសដំណឹងល្អអំពីសេចក្តីស្រលាញ់នេះដែលមានគ្រឹះដ៏រឹងមាំចេញពីព្រះបិតា។ ខ្ញុំដែលបានជ្រើសរើសផ្លូវមួយដើម្បីឆ្លើយតបតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ តើខ្ញុំបានប្រព្រឹត្តសមរម្យតាមមុខងារខ្លួនហើយឬនៅ ? យើងជាគ្រីស្តបរិស័ទជឿព្រះយេស៊ូ ជាព្រះអម្ចាស់ ហើយយកកំណើតជាមនុស្សដូចយើង និងលះបង់ជីវិតទ្រង់ទាំងស្រុងនៅលើឈើឆ្កាងដើម្បីប្រកាសអំពីសេចក្តីស្រលាញ់ដែលហូរចេញមកពីព្រះបិតាសម្រាប់មនុស្សដែលជាគំរូយ៉ាងប្រសើរឱ្យយើងប្រតិបត្តិតាម។ ដូច្នេះដើម្បីឱ្យសេចក្តីស្រលាញ់មានការរីកចម្រើន យើងត្រូវមានគ្រឹះមួយជាប់នឹងសេចក្តីស្រលាញ់នៃព្រះជាម្ចាស់ជាព្រះបិតា និងព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើង គឺជាសេចក្តីស្រលាញ់ដែលបង្រួបបង្រួមយើងឱ្យទៅជាធ្លុងតែមួយរួមនឹងព្រះអង្គ។

អ្នកនាំសារ

## ពង្រឹងសហប្រតិបត្តិការ


Photo: L. Sovanna

យុវជន-នារី នៃព្រះសហគមន៍សៀមរាប បានចាកចេញពីប្រទេសកាលពីថ្ងៃទី២៥ ឧសភា ឆ្ពោះទៅប្រទេសអង់គ្លេសដើម្បីបំពេញទស្សនៈកិច្ចចំនួនប្រាំសប្តាហ៍។ មុនចេញដំណើរ លោកធីម ធន់ បានឱ្យដឹងថា: "ដំណើរនេះដើម្បីរឹតចំណងមិត្តភាពរវាងព្រះសហគមន៍សៀមរាប ភូមិភាគបាត់ដំបងជាមួយនិងព្រះសហគមន៍នៅអង់គ្លេសខាងកើតឱ្យកាន់តែល្អប្រសើរ និងបង្ហាញពីសកម្មភាពខ្លះៗអំពីព្រះសហគមន៍សៀមរាបភូមិភាគបាត់ដំបង និងព្រះសហគមន៍នៅប្រទេសកម្ពុជាទាំងមូលផងដែរ"។ សូមរំឭកថា ព្រះសហគមន៍ភូមិភាគបាត់ដំបង និងព្រះសហគមន៍នៅប្រទេសអង់គ្លេសខាងកើតបានចងសម្ព័ន្ធភាពនឹងគ្នាជាបងប្អូនតាំងពីឆ្នាំ១៩៩៧។ សុវណ្ណា

## "ខ្ញុំស្រឡាញ់បងប្អូនកម្ពុជា"


Photo: Ramon

កាលពីល្ងាច ថ្ងៃព្រហស្បតិ៍ ទី១៨ ឧសភា ឆ្នាំ២០០៦ នៅព្រះសហគមន៍បាត់ដំបង មានរៀបចំពិធីអរគុណបងស្រីអេលីណា ជាជនជាតិអេស្ប៉ាញ ដែលបានជួយការងារនៅមណ្ឌលសុខភាពរយៈពេលមួយឆ្នាំ មុននឹងបងស្រីត្រឡប់ទៅស្រុកកំណើតរបស់គាត់វិញនៅថ្ងៃទី២០ ឧសភា។ ក្នុងពិធីនោះ មានការចូលរួមពីលោកអភិបាល បងស្រីវើជីណា បងស្រីអាន់ជីលា កុមារាកុមារី បុគ្គលិកមណ្ឌលអារ៉ុបពេ ព្រមទាំងបុគ្គលិកនៅមណ្ឌលសុខភាពផងដែរ។ បងស្រីអេលីណា បានមានប្រសាសន៍ថា: "ខ្ញុំយល់ថាប្រជាជនខ្មែរគឺមានរបៀបមួយសប្បាយរីករាយណាស់ ធ្វើឱ្យខ្ញុំមានចិត្តចង់ជួយ និងនៅជាមួយពួកគេដោយសេចក្តីស្រលាញ់។ សុជាតិ

## អេម៉ាន្ទូអែល

សម្លេងពីព្រះសហគមន៍កាតូលិក

បាត់ដំបង: FM 91.0 Mhz
ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

ភ្នំពេញ: FM 99.5 Mhz
ម៉ោង ៧:០០-៧:៣០ រាល់ល្ងាចថ្ងៃសៅរ៍។

## យុវជនចូលរួមសំណាក់ធម៌

នៅថ្ងៃទី០៧ ខែឧសភា សាលាបណ្ដុះបណ្ដាលវិជ្ជាជីវដុនបូស្កូ ទឹកថ្លា មានរៀបចំពិធីសំណាក់ធម៌តេហ្សេ សម្រាប់យុវជនចំនួន ៥០នាក់ មកពី ៣ភូមិភាគ ដោយមានការអញ្ជើញចូលរួមពីបងប្រុសគីឡាំង ដែលជាជនជាតិបារាំង មកពីសហគមន៍តេហ្សេ នៅប្រទេសបារាំង។ បងប្រុសគីឡាំង និយាយថា: "វាជាសញ្ញានៃការរួបរួមគ្នាជាធ្លុងតែមួយ និងសាមគ្គីភាព ធ្វើឱ្យយើងមានអារម្មណ៍ជិតស្និទ្ធជាមួយយុវជនកម្ពុជា។ យើងរីករាយចំពោះអ្វីដែលគេផ្តល់ឱ្យយើងប្រៀបដូចជាគ្រួសារតែមួយដែលបានមកជួបជុំគ្នា។ ពេលឃើញយុវជនបង្ហាញសក្ខីភាពនៃព្រះសហគមន៍របស់ខ្លួន ខ្ញុំពោរពេញដោយក្តីសង្ឃឹម និងសរសើរដល់ការរិះគិត និងសកម្ម[illegible] ធារី


Photo: Donbosco Sister

## ចេញលក់ហើយ!

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិកមានចេញផ្សាយ CD ចម្រៀងវ៉ុលទី៣ថ្មី ឈ្មោះ "វិញ្ញាណព្រះអម្ចាស់" ដែលសុទ្ធសឹងជាបទចម្រៀងលើកតម្កើងព្រះជាម្ចាស់។ CD មួយវ៉ុលនេះ មាន១០បទ ដោយមានថែមសន្លឹកអក្សរចម្រៀង និងអក្សរភ្លេងផងដែរលក់ក្នុងតម្លៃធម្មតាតែ ២$ ប៉ុណ្ណោះ។ ដូច្នេះបើសិនបងប្អូន ឬប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវ CD នេះ សូមទាក់ទងមកកាន់ការិយាល័យយើងខ្ញុំ។ ទូរស័ព្ទ: ០២៣ ២២៤ ១២០ ឬ ០១២ ២៤៤ ៧៧៨។

សូមអរគុណ!





## សិក្ខាសាលាគ្រូមត្តេយ្យព្រះសហគមន៍កាតូលិក

កាលពីថ្ងៃទី២២-២៣ ឧសភា ឆ្នាំ២០០៦ នៅព្រះវិហារកាតូលិកផ្សារតូច មានរៀបចំអង្គសិក្ខាសាលាសម្រាប់គ្រូសាលាមត្តេយ្យកាតូលិក។ អង្គសិក្ខាសាលានេះរៀបចំដោយគណៈកម្មការអប់រំចំណេះដឹងទូទៅ ដែលមានសិក្ខាកាមចូលរួម ៣០នាក់ មកពីខេត្ត-ក្រុង ក្នុងភូមិភាគភ្នំពេញ។ លោកបូជាចារ្យអូលីវីយេ ជាប្រធានក្រុមគណៈកម្មាធិការនេះ មានប្រសាសន៍ថា: "ក្រុមនេះចាប់ផ្តើមឡើងតាំងពីខែកញ្ញា ឆ្នាំ២០០៥មកម្ល៉េះ ហើយនេះជាលើកទី៤ នៃសិក្ខាសាលាសម្រាប់គ្រូមត្តេយ្យនេះ។ ការរៀបចំគឺដោយសារតែមានសំណូមពរពីគ្រូមត្តេយ្យទាំងនេះដើម្បីទទួលការអប់រំបន្ថែម រីឯគោលបំណងនៃសិក្ខាសាលា គឺហ្វឹកហ្វឺនបច្ចេកទេសក្នុងការធ្វើសកម្មភាពជាមួយក្មេងៗ ដូចជាកាត់ក្រដាស ធ្វើរូបភាពលំហាត់ប្រាណ និងការធ្វើអនាម័យជាដើម"។ លោកបូជាចារ្យបានបន្តថា: "សាលាមត្តេយ្យយើងគឺចាប់អារម្មណ៍ចំពោះក្មេងៗដោយសារយើងចង់ឱ្យគេធំឡើងក្លាយជាពលរដ្ឋខ្មែរល្អម្នាក់។ យើងសុំឪពុកម្តាយក្មេងៗផ្តល់អង្ករ ១គីឡូក្រាម ក្នុងមួយខែ។ សម្រាប់ក្មេងដែលមករៀន យើងមានឱ្យអាហារដល់ពួកគេមួយពេល ក្នុងម៉ោងរៀន និងនំចំណីផ្សេងៗ នៅពេលសំរាក"។ ធារី


Photo: H. Soktheary

## ព្រះសហគមន៍រឹតចំណងទាក់ទងនឹងឥស្លាមសាសនា


Photo: L. Sovanna

អង្ករ ២តោន ដែលជាអំណោយរបស់លោកលូកា ដឺម៉ាតា ជានាយកសារព័ត៌មាន រីដេស ប្រចាំនៅបុរីវ៉ាទីកង់តាមរយៈព្រះសហគមន៍កាតូលិក ត្រូវបានយកទៅចែកជូនដល់បងប្អូនប្រជាពលរដ្ឋក្រីក្រ ចំនួន ៣០០គ្រួសារ ជាសាសនិកឥស្លាម នៅភូមិឈូកក្រញ៉ាស់ ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២ មិថុនា ឆ្នាំ២០០៦ កន្លងទៅ។ ពិធីនេះមានការចូលរួមអំពីឯកឧត្តមអ៊ីប្រាហ៊ីម ដែលជារដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា លោកបូជាចារ្យ ប៉ុយ ណូ បូជាចារ្យអ៊ុន សុន លោកលូកា ដឺម៉ាតា និងប្រជាពលរដ្ឋជាសាសនិកឥស្លាមយ៉ាងច្រើនកុះករ។ នៅក្នុងពិធីនេះ លោកបូជាចារ្យ ប៉ុយ ណូ ក៏បានបញ្ជាក់ដែរថា: "នេះគឺជាសញ្ញាណមួយដ៏ប្រសើរក្នុងការកសាងទំនាក់ទំនងគ្នារវាងឥស្លាម ជាមួយនិងព្រះសហគមន៍"។ លោកលូកា យល់ស្របនិងចំនុចខាងលើ និងបានបន្ថែមទៀតថា: "អ្នកដឹកនាំសាសនាផ្សេងៗ ជួបជុំគ្នានៅថ្ងៃនេះ និងនៅថ្ងៃអនាគតដើម្បីយល់គ្នា និងការកសាងសន្តិភាព"។ ចំណែកឯកឧត្តមអ៊ីប្រាហ៊ីម មានប្រសាសន៍ថា: "ការចែកអំណោយនៅថ្ងៃនេះគឺមិនមានការរើសអើង និងក៏មិនមានប្រកាន់និន្នាការនយោបាយអ្វីឡើយ"។ ជាពិសេស ឯកឧត្តមបានសង្កត់ធ្ងន់ថា: "នេះគឺជាការចូលរួមរបស់សាសនាជាមួយរដ្ឋាភិបាលដើម្បីកាត់បន្ថយនូវភាពក្រីក្រ"។ លី សុវណ្ណា

## ប្រជុំរៀបចំសន្និសីទអន្តរភូមិភាគ

នៅព្រះសហគមន៍បាត់ដំបង កាលពីថ្ងៃទី៥ ឧសភា ឆ្នាំ២០០៦ មានការជួបជុំរបស់គណៈកម្មការមកពីគ្រប់តំបន់ក្នុងភូមិភាគបាត់ដំបង ដូចជាតំបន់កំពង់ធំ អង្គរ និងតំបន់ទន្លេ ក្រោមការដឹកនាំរបស់លោកបូជាចារ្យទម្លាប់ សុផល លោកហ្វ្រង់កូរ និងលោកហៃរណាន់។ ការប្រជុំរបស់លោកបូជាចារ្យទាំងអស់ គឺពិភាក្សានៅលើប្រធានបទត្រៀមទុកសម្រាប់ណែនាំក្នុងអង្គសន្និបាតធំ នាខែកក្កដាខាងមុខ នៅរាជធានីភ្នំពេញ។ ភីរុណ

## សប្បាយនឹងការងារថ្មីពីព្រះជាម្ចាស់

នៅថ្ងៃទី០៤ ឧសភា ឆ្នាំ២០០៦ នៅមណ្ឌលសន្តវ៉ាំងសង់ ដឺប៉ូល បាត់ដំបង តាហែន និងតាពូង មានកម្មវិធីសម្រាប់កុមារា កុមារី និងយុវជន បន្ទាប់ពីបងស្រីមែកស៊ី និងបងស្រីយូលី បានប្តូរបេសកកម្មទៅព្រះសហគមន៍ នៅប្រទេសថៃ ដោយមានបងស្រី២នាក់ គឺបងស្រីវើជីណា អ្នកថែរក្សាអ្នកជំងឺនៅព្រះសហគមន៍ផ្សារតូច ភ្នំពេញ និងបងស្រីប្រាណស៊ីស មកបន្តការងារជំនួស។ បងស្រីទាំង២នាក់ ជាជនជាតិហ្វីលីពីន។ បងស្រីវើជីណា មានចំណាប់អារម្មណ៍ថា: "ខ្ញុំសប្បាយរីករាយណាស់នឹងការងារនេះ គឺខ្ញុំបានធ្វើការ និងនៅជាមួយក្មេងៗ ព្រមទាំងយុវជន ហើយខ្ញុំក៏មានការត្រេកអរខ្លាំងណាស់ដែលខ្ញុំបានមកជំនួសបងស្រីមែកស៊ី និងបងស្រីយូលី ដែលគាត់ទាំង២នាក់ បាន[illegible]"។ សុជាតិ

# ធ្វើទស្សនកិច្ចដើម្បីឱ្យក្រុមមានសាមគ្គីភាពរឹងមាំ

កាលពីថ្ងៃទី១៥-១៧ ឧសភា ព្រះសហគមន៍កាតូលិកផ្សារតូច បានរៀបចំវិស្សមកាលសម្រាប់ក្រុមអនុគណៈកម្មការទាំង៣ ដោយមានគ្នាសរុប ៨០


ក្រុមគណៈកម្មការថតរូបជាអនុស្សាវរីយ៍នៅមាត់សមុទ្រក្រុងកែប

Photo: Fr. Xavier

នាក់ទៅកំសាន្តនៅក្រុងកែប ខេត្តកំពត។ លោកបូជាចារ្យអ៊ិន សុន មានមតិទៅកាន់អនុគណៈកម្មការទាំង៣ ថា: “ខ្ញុំចូលចិត្តឃ្លាមួយក្នុងធម៌ ឱ! ព្រះបិតា គឺសូមឱ្យអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឱ្យអ្នកដែលប្រព្រឹត្តខុសនឹងយើងខ្ញុំ”។ ឃ្លានេះ ព្រះយេស៊ូបង្ហាញថា ព្រះអង្គស្រឡាញ់មនុស្សបាប។ ព្រះអង្គចង់ឱ្យយើងចេះជួយគេ។ ដូច្នេះ៣ថ្ងៃនេះ គឺជាពេលវេលាឱ្យយើងរិះគិតរួមគ្នា និងពិនិត្យមើលទៅលើសកម្មភាពរបស់យើង ដែលមកពីព្រះជាម្ចាស់”។ លោកបូជាចារ្យបប់ ពីស្សេ មានប្រសាសន៍ថា: “ខ្ញុំចង់ឱ្យគេស្គាល់អំពីគុណវិបត្តិ និងគុណសម្បត្តិរបស់គេ ដើម្បីអរគុណដល់ព្រះជាម្ចាស់ និងពង្រឹងសាមគ្គីភាពជាមួយគ្នានៅក្នុងគុណភាពការងារ ដោយមិនគិតតែពីការងារ [illegible]”។

ធារី

## ព្រះសហគមន៍នៅតែនឹកដល់អ្នក ដែលលាចាកលោក

លោកអភិបាលអេមីល ដេតម្បូ រួមជាមួយសាច់ញាតិមួយចំនួនរបស់លោកអភិបាលឆ្នាសាឡាស់ លោកបូជាចារ្យឆ្នា សាឡឹម និងលោកបូជាចារ្យទ្រឿង ចំរើន បានរួមគ្នាទៅអធិដ្ឋាននៅនឹងផ្នូរមរណៈសាក្សី ឬផ្នូរនៃក្ដីសង្ឃឹម ស្ថិតនៅព្រះសហគមន៍តាំងគោក កាលពីថ្ងៃទី៧ ឧសភាកន្លងទៅ ដែលជាថ្ងៃបុណ្យគោរពមរណៈសាក្សីនៅប្រទេសកម្ពុជា។ លោកអភិបាលអេមីល មានប្រសាសន៍ថា: “យើងមានអំណរសប្បាយណាស់ ដែលបានមកដល់ផ្នូរមរណៈសាក្សី ឬផ្នូរនៃក្ដីសង្ឃឹម និងរួមគ្នាអរព្រះគុណព្រះជាម្ចាស់ អធិដ្ឋានរំលឹកដល់បងប្អូនទាំងនោះ ដែលបានស៊ូប្ដូរជីវិតដើម្បីរក្សានូវជំនឿរបស់ខ្លួន”។ នៅកម្ពុជា មានមរណៈសាក្សីជាច្រើនបង្ហាញនូវចិត្តស្មោះត្រង់របស់ខ្លួនដោយសុខចិត្តរងទុក្ខវេទនាគ្រប់យ៉ាងព្រោះតែព្រះគ្រីស្ដជាព្រះអម្ចាស់។

វណ្ណា


Photo: L. Sovanna

លោកអភិបាលអេមីល ដេតម្បូ ចូលសំរាក និងសំណេះសំណាលក្នុងខ្ទមមរណៈសាក្សី

## “កុមារគ្រប់រូបត្រូវការគ្រូល្អ”

នេះ គឺជាប្រធានបទក្នុងកម្មវិធីអបអរសាទរ ការប្រកាសលទ្ធផលនៃយុទ្ធនាការជាសកលសម្រាប់ការអប់រំ ២០០៦ នាថ្ងៃទី២៥ ឧសភា ដែលមានការចូលរួមពីឯកឧត្តមទៀ បាញ់ ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាតំណាងដ៏ខ្ពង់ខ្ពស់នៃសម្ដេចហ៊ុន សែន ព្រមទាំងភ្ញៀវជាតិ អន្តរជាតិ អង្គការផ្សេងៗ ដូចជា អង្គការមិត្តសំឡាញ់ គ្រូសារថ្មី មនុស្សលោកថ្មី និងជាពិសេសក៏មានការចូលរួមពីសំណាក់លោក-អ្នកគ្រូ សិស្សានុសិស្ស និងក្មេងៗពិការផងដែរ។



Photo: M. Kunthear

នាឱកាសនោះ ឯកឧត្តមទៀ បាញ់ ក៏មានចំណាប់អារម្មណ៍ និងមានមតិផ្ដាំផ្ញើថា: “ការអប់រំគឺមិនមែនគ្រាន់តែជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដែលមានក្រសួងអប់រំយុវជន និងកីឡាជាសេនាធិការប៉ុណ្ណោះទេ ប៉ុន្តែវាជាកិច្ចការសម្រាប់ប្រជាពលរដ្ឋគ្រប់រូប និងគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់”។ រាជរដ្ឋាភិបាលបានផ្ដល់សច្ចាប័ន ទៅលើអនុសញ្ញានានាស្ដីពីសិទ្ធិកុមារ សំដៅលើកកម្ពស់ និងផ្ដល់សិទ្ធិ ឱ្យកុមាររាល់រូប រួមទាំងកុមារពិការ និងកុមាររងាយរងគ្រោះដើម្បីឱ្យពួកគេទទួលបានសិទ្ធិ មូលដ្ឋានទាំង៤ គឺមានសិទ្ធិរស់រានមានជីវិត សិទ្ធិក្នុងការការពារ សិទ្ធិទទួលការអភិវឌ្ឍន៍ និងសិទ្ធិក្នុងការចូលរួម។ ទិវានេះបញ្ចប់ទៅ ដោយទឹកមុខរីករាយ និងបង្ហោះប៉េងប៉ោងផងដែរ។

មុំ គន្ធា





# ពិធីច្រត់ព្រះនង្គ័ល: ការផ្សងគោឧសភរាជបង្ហាញថាការដាំដុះនឹងបានផលល្អ

តំណាងឱ្យការចាប់ផ្ដើមរដូវភ្ជួររាស់ ពិធីច្រត់ព្រះនង្គ័លត្រូវបានប្រារព្ធធ្វើឡើងកាលពីថ្ងៃទី១៦ ឧសភាកន្លងទៅ ក្រោមព្រះរាជអធិបតីភាពព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថនរោត្តមសីហមុនី និងមានមនុស្សរាប់ពាន់នាក់ មកជួបជុំគ្នានៅវាលព្រះមេរុដែលជា “វាលព្រះស្រែ”។ នៅក្នុងពិធីនោះ ឯកឧត្តមឃួ ហុកគ្រី ជាអនុប្រធានទី២ រដ្ឋសភាជាតិ ត្រូវបានជ្រើសជាតំណាងស្ដេចមាឃ ហើយភរិយាលោកជាមេហួ។

តាមទំនៀមទម្លាប់ប្រពៃណីពីបុរាណ គោឧសភរាជត្រូវបានគេផ្សងដោយដឹកឱ្យទៅបរិភោគចំណី ៧មុខ រួមមាន ស្រូវ ពោត សណ្ដែក ល្ង ទឹក ស្រា និងស្មៅ។ ពេលចាប់ផ្ដើម គេសង្កេតឃើញគោឧសភរាជបរិភោគ ស្រូវ ពោត និងសណ្ដែក ធ្វើឱ្យប្រជាកសិករយើងទាំងអស់ដែលចូលរួមពិធីមានការត្រេកអរយ៉ាងខ្លាំង ពីព្រោះ វាជាប្រផ្នូលថាភោគផលដំណាំនឹងឱ្យទិន្នផលយ៉ាងល្អប្រសើរនៅក្នុងឆ្នាំ២០០៦នេះ។ ក្រោយពេលគោឧសភរាជបរិភោគរួច លោកបាគូពោលថា: “ស្រូវត្រូវគោឧសភរាជបរិភោគចំនួន ៩៥% សណ្ដែកចំនួន ៨០% ពោតចំនួន ៧៥% និងស្មៅ ៥០%”។ ទំនាយទាយថា: “ស្រូវ សណ្ដែក ពោត ឆ្នាំនេះនឹងទទួលបានផលល្អជាទីគាប់ចិត្ត”។ ចំណែកស្មៅដែលគោបរិភោគចំនួន ៥០% មិនចោទជាបញ្ហាអ្វីនោះទេ ព្រោះថាស្មៅជាចំណីអាហារប្រចាំថ្ងៃរបស់ពាហនៈទូទៅ។

លី សុវណ្ណា


Photo: L. Sovanna

គោឧសភរាជឆ្នាំនេះបរិភោគស្រូវ សណ្ដែក និងពោតច្រើន



Photo: L. Sovanna

ប៉ាណូក្នុងអគ្គន័យប្រឆាំងគ្រឿងញៀនរបស់អាជ្ញាធរជាតិ

## គ្រឿងញៀនជាចំណីបំផ្លាញជីវិត

គ្រឿងញៀនបានបំផ្លាញសុខភាព ការរស់នៅ សន្តិសុខ និងសង្គមជាតិទាំងមូលរបស់យើង ដោយសារវាប៉ះពាល់ភាគច្រើនទៅលើយុវជន។

របាយការណ៍លទ្ធផលការងាររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបង្ហាញថា ឆ្នាំ២០០៥ សមត្ថកិច្ចអនុវត្ត ច្បាប់បង្ក្រាបបទល្មើស សរុបចំនួន ៣៦៦ករណី ដែលកើន ៦៨,៧% និងចាប់ខ្លួនជនល្មើសបានចំនួន ៧០៩នាក់ កើនឡើង ៤៥% បើប្រៀបធៀបឆ្នាំ២០០៤ មានតែ ២១៧ករណី និងចាប់បានជនល្មើស ៤៨៩នាក់។ របាយការណ៍ដដែលបញ្ជាក់ថា អ្នកញៀនគ្រឿងញៀន មានចំនួនកើនឡើងជារៀងរាល់ឆ្នាំ ដូចជា ឆ្នាំ២០០០ មាន ៩៩១នាក់ ឆ្នាំ២០០១ មាន ៩២៨នាក់ ឆ្នាំ២០០២ មាន ២៧៥០នាក់ ឆ្នាំ២០០៣ មាន ៤៣៨៧នាក់ ឆ្នាំ២០០៤ មាន ៥៥០២នាក់ និង២០០៥ មាន ៦៨៧៦នាក់។ ភាគច្រើននៃអ្នកទាំងអស់នេះគឺជាមនុស្សពេញវ័យ និងជាយុវជនវ័យជំទង់ដែលមានអាយុតិចជាង ១៨ឆ្នាំ។ ម្យ៉ាងទៀត ពពួកគ្រឿងញៀនមានច្រើនប្រភេទដូចជា គ្រឿងញៀនសំយោគ ATS មេអំហ្វេតាមីន អ៊ិចស្តាស៊ី ហេរ៉ូអ៊ីន កញ្ឆា និងកេតាមីន-ល-។ ពួកវាហូរចូលកម្ពុជាតាមច្រកមួយចំនួនតាមព្រំដែនថៃ និងឡាវ ដែលមានច្រកបីសំខាន់ៗ មានច្រករបស់ ស្រុកថាឡាបរិវ៉ាត់ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង និងច្រករបស់ស្រុកឆែប ខេត្តព្រះវិហារ។ ការទប់ស្កាត់គ្រឿងញៀននៅកម្ពុជាពុំមានប្រសិទ្ធភាពខ្ពស់ គឺដោយសារមានអំពើពុករលួយ និងប្រព័ន្ធតុលាការមានភាពទន់ជ្រាយ ដូចមានការដោះលែងនូវជនជាប់ចោទទាក់ទិននឹងការចរាចរណ៍គ្រឿងញៀន។ នេះបើតាមរបាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅដើមខែមីនា ឆ្នាំ២០០៦។

មុំ គន្ធា

ការរំលោភសេពសន្ថវៈលើអនីតិជន (កុមារមិនទាន់គ្រប់អាយុ) គឺជាអំពើមួយ ដែលសង្គម និងមនុស្សជាច្រើនមិនថា នៅប្រទេសកម្ពុជា ឬនៅទូទាំងពិភពលោក មានការស្អប់ខ្ពើម និងដាក់ទោសចំពោះអ្នកប្រព្រឹត្តអំពើនេះជាទីបំផុត។ ករណីរំលោភសេពសន្ថវៈលើកុមារនេះកំពុងតែមានការកើនឡើងយ៉ាងខ្លាំងដោយមិននឹកស្មានដល់។ ជនដែលប្រព្រឹត្តអំពើបែបនេះប្រៀបបីដូចជា មនុស្សដែលគ្មានវិចារណញាណ អមនុស្សធម៌ និងជាមនុស្សដែលគ្មានតម្លៃអ្វីឡើយនៅក្នុងសង្គម។ តើមូលហេតុអ្វី ដែលបណ្តាលឱ្យមានអំពើនេះកើតមាននៅក្នុងសង្គមកម្ពុជា? តើនរណាជាអ្នកប្រឈមមុខចំពោះបញ្ហាអស់ទាំងនេះ?

# កំណើននៃអំពើរំលោភសេពសន្ថវៈ



Photo: Licadho

កុមារត្រូវការយល់ដឹងអំពីសិទ្ធិ និងអាចទទួលការអប់រំអំពីការការពារខ្លួនពីសំណាក់រាល់អំពើរំលោភបំពានមកលើផ្លូវភេទ


Photo: K. Kagha

បើសិនប្រិយមិត្តទាំងឡាយមានចំណាប់អារម្មណ៍ចង់ជជែកពិភាក្សាអំពីអត្ថបទនេះ សូមផ្ញើសំបុត្រមកកាន់ការិយាល័យព្រឹត្តិបត្រ "អ្នកនាំសារ" តាមរយៈលោកឪពុក បងប្រុស-បងស្រីដែលនៅជិតបំផុត។

## តួលេខដែលគួរឱ្យព្រួយបារម្ភ

ការចាប់រំលោភមានច្រើនប្រភេទ វាមិនមែនតែទៅលើរាងកាយតែប៉ុណ្ណោះទេ វាមានលើផ្លូវចិត្ត ផ្លូវអារម្មណ៍ ផ្លូវភេទ និងលើសេដ្ឋកិច្ចផងដែរ។ ការរំលោភទៅលើផ្លូវភេទនោះ គឺជាការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស់ ទៅលើជនរងគ្រោះនៅក្នុងគ្រួសារ និងក្រៅគ្រួសារផងដែរ។

ករណីរំលោភសេពសន្ថវៈលើកុមារ ជាអំពើមួយរំលោភដល់សិទ្ធិ កុមារដែលកំពុងកើតមានឡើងយ៉ាងធ្ងន់ធ្ងរ និងគួរឱ្យព្រួយបារម្ភបំផុតនៅប្រទេសកម្ពុជាបច្ចុប្បន្ននេះ។

ឆ្លងតាមរបាយការណ៍របស់អង្គការអាដហុក ចាប់តាំងពីខែមករា ដល់ខែធ្នូ ឆ្នាំ២០០៥ អង្គការទទួលបាន ៣៨០ករណី នៅក្នុង ២៤ខេត្ត-ក្រុង ដែលភាគច្រើនលើសលប់នៃជនរងគ្រោះដោយការរំលោភ គឺជាកុមារដែលមានចំនួនរហូតដល់ ២៨៤នាក់ ត្រូវនឹង ៧៧% នៃ ៣៨០ករណី ក្នុងនោះ កុមារអាយុក្រោម ១០ឆ្នាំ មានចំនួន ៨២នាក់ ស្មើនឹង ២៤% និងអាយុចន្លោះពី ១១-១៧ឆ្នាំ មានចំនួន ១៩២នាក់ ដែលស្មើនឹង ៥៣%។ ចំណែកស្ត្រីរងគ្រោះ ដែលមានអាយុពី ១៨ឆ្នាំឡើង គឺមានចំនួន ៩២នាក់ ស្មើនឹង ២៣% នៃ ៣៨០ករណីនោះ។ តួលេខនេះអាចបង្ហាញឱ្យឃើញថា ការចាប់រំលោភដែលជនរងគ្រោះជាកុមារ គឺមានចំនួនកើនឡើងគួរឱ្យព្រួយបារម្ភ ព្រោះបើធ្វើការប្រៀបធៀបទៅនឹងឆ្នាំ ២០០៤ មានតែ ៦១% នៅក្នុងចំណោម ៣២៦ករណី។ ចំនួននេះអាចជាចំនួនពុំពិតប្រាកដ បើប្រៀបធៀបនឹងបញ្ហាជាក់ស្តែង ដែលកើតមាន ដោយសារថាជនរងគ្រោះមួយចំនួននៅតំបន់ដាច់ស្រយាលមិនស្គាល់អ្វីដែលជាច្បាប់ និងពុំដឹងអាចរកជំនួយពីទីណាបាន និងមួយចំនួនទៀតមានការភ័យខ្លាចអំពីបញ្ហាសន្តិសុខផ្ទាល់ខ្លួន។ ដូច្នេះពួកគេពុំមករាយការណ៍។ ហើយចំពោះករណីរំលោភទាំងនេះ ភាគច្រើនជនល្មើស និងជនរងគ្រោះ គឺជាមនុស្សធ្លាប់ស្គាល់គ្នា មានរហូតដល់ទៅ ៧៣% នៃករណី ដូចជាជនល្មើស ជាឪពុកបង្កើត មាន ២,៨៦% ជាឪពុកចុង មាន ៧% និងជាឪពុកមា មាន ២%។

ចំណែករបាយការណ៍របស់មន្ត្រីជំនាញ ទទួលបន្ទុកផ្នែកសិទ្ធិកុមាររបស់អង្គការលីកាដូ ក៏បានឱ្យដឹងដែរថា ករណីរំលោភសេពសន្ថវៈលើកុមារក្រោមអាយុ ១៨ឆ្នាំ កើនឡើង នៅឆ្នាំ ២០០៥ ដែលមាន ២០៥ករណី ហើយជនរងគ្រោះមានចំនួន ២០៧នាក់ និងជនល្មើសមានចំនួន២១៦នាក់ ដែលធៀបនឹងឆ្នាំ២០០៤ មានតែ ១៩០ករណី ដែលជនរងគ្រោះមានចំនួន ១៩២នាក់ និងជនល្មើសមានចំនួន ១៩៤នាក់។ មន្ត្រីរូបនេះនិយាយថា ករណីនេះច្រើនកើតមាននៅតាមបណ្តាខេត្ត ដូចជា កំពង់ចាម កំពង់ធំ បាត់ដំបង និងខេត្តកណ្តាល និងច្រើនកើតលើគ្រួសារណាដែលរស់ឆ្ងាយពីទីប្រជុំជន ទាល់ក្រ ខ្វះខាតការអប់រំដោយកត្តាជីវភាព និងភូមិសាស្ត្រជាដើម។

### តើអ្វីទៅជាអំពើរំលោភបួក?

ការរំលោភបួកគឺជាអំពើមួយដ៏កាចសាហាវ ព្រោះអ្នកដែលប្រព្រឹត្តនោះភាគច្រើនជាក្រុមក្មេងស្ទាវដែលមានចំនួនចាប់ពី ២នាក់ ឬរហូតអាចដល់ ៥នាក់ ដោយការប្រព្រឹត្តិលើមនុស្សស្រីមិនថានៅលីវ ឬមានគ្រួសារទេឱ្យតែដើរជួបជាមួយបក្សពួករបស់វា។ អាយុរបស់ក្រុមនេះចាប់ពី១២ឆ្នាំ ឡើងទៅ ហើយពួកគេច្រើនតែជាសិស្សសាលាផងដែរ។

បើយោងតាមរបាយការណ៍ថ្នាក់ជាតិស្តីអំពីឥរិយាបថប្រកបដោយគ្រោះថ្នាក់របស់កុមារ ចាប់ពីអាយុ ១១ឆ្នាំ ដល់ ១៨ឆ្នាំ ក្នុងឆ្នាំ២០០៣-២០០៤ បានបង្ហាញដែរថា មានយុវវ័យចំនួន១/៣ ក្នុងចំណោមយុវវ័យ ៩៨៣៣នាក់ បានឱ្យដឹងថាពួកគេបានចូលរួមក្នុងការចាប់រំលោភជាក្រុម ក្នុងនោះ មាន ៥៩% គឺជាសិស្សសាលា និង៤១% ជាយុវវ័យក្រៅសាលា។ ចំពោះនៅឆ្នាំ២០០៥ អ្នកដែលចាប់រំលោភជាក្រុមនេះ មានអាយុកាន់តែតិចជាងឆ្នាំមុន ចាប់ពីអាយុ ៧ឆ្នាំឡើង និងជាសិស្សសាលាទៀត។ តាមការសង្កេត នៅឆ្នាំ២០០៤ ករណីរំលោភជាក្រុម ដែលសមាគមអាដហុកទទួលបាន គឺមានតែ ២១ករណីប៉ុណ្ណោះ ប៉ុន្តែឈានដល់ ឆ្នាំ២០០៥ ករណីរំលោភជាក្រុម បានកើនឡើងដល់ ២៥ករណី។

## មូលហេតុធ្វើឱ្យកើតមានឡើង

លោកស្រីលឹម មុនី ប្រធានផ្នែកស្ត្រីនៃអង្គការអាដហុក បានមានប្រសាសន៍ឱ្យដឹងថា: "ការរំលោភសេពសន្ថវៈ ទៅលើកុមារ នៅតែមានសន្ទុះកើនឡើងឥតឈប់ឈរ នៅប្រទេសកម្ពុជា ដែលនៅដើមឆ្នាំ២០០៦នេះ នៅតាមបណ្តាខេត្តមួយចំនួនមានការកើនឡើងយ៉ាងខ្លាំងក្លា ដូចជា ខេត្តពោធិ៍សាត់ កំពង់ស្ពឺ និងខេត្តកំពង់ធំជាដើម"។ ក្នុងនេះដែរ មានកត្តា ៤ ចម្បងៗ ដែលធ្វើឱ្យកើតមានឡើងនូវអំពើ ដែលសង្គមស្អប់ខ្ពើមនេះ។ កត្តាទី១ សីលធម៌សង្គមមានការស្រុតចុះ ដោយម្នាក់ៗលែងដឹងពីបាបបុណ្យអ្វីឡើយ សូម្បីតែឪពុកបង្កើតក៏ចាប់រំលោភកូនខ្លួនឯងដែរ។ កត្តាទី២ ភាពក្រីក្របានបង្ខំឱ្យក្មេងៗ និងស្ត្រីមួយចំនួនបង្ខំចាកចេញទៅរកការងារធ្វើ នៅតាមទីក្រុង ដែលធ្វើឱ្យពួកគេចាញ់បោកជនខិលខូច។ មួយចំនួនត្រូវយកទៅលក់ ហើយនិងមួយចំនួនទៀតត្រូវគេចាប់រំលោភ។ កត្តាទី៣ គឺប្រព័ន្ធតុលាការនៅមានកម្រិត ដោយការអនុវត្តន៍ច្បាប់នាពេលបច្ចុប្បន្ននេះ នៅមិនទាន់មានស្តង់ដារនៅឡើយ ហើយកត្តាទី៤ គឺមានការហូរចូលនូវវប្បធម៌បរទេស ដែលបញ្ហានេះ ធ្វើឱ្យយុវវ័យ ក៏ដូចជា មនុស្សមួយចំនួនទៀតមានការឈ្លក់វង្វេង។ម្យ៉ាងវិញទៀត ក៏មានការបញ្ចាំងវីដេអូអាសអាភាសជាដើម។

លោកយឹម ប៉ូ នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីការពារសិទ្ធិកុមារ បានបន្ថែមលើចំនុចនេះថា: "ដោយការហូរចូលនៃវប្បធម៌បរទេស ការសេពគ្រឿងញៀន ហើយជាពិសេស គឺការអប់រំនៅមានភាពទន់ខ្សោយ វាធ្វើឱ្យមនុស្សយើងមានការវង្វេង ភ្លើតភ្លើនទៅតាមសំភារៈនិយម ដែលបានមកពីទំនើបភាវូបនីយកម្ម ទាំងក្នុងទីក្រុង និងតាមជនបទ ធ្វើឱ្យអំពើរំលោភនេះកើតមានច្រើនឡើងៗ"។ លោកបានបញ្ជាក់យ៉ាងធ្ងន់ថា: "មិនមែនបុគ្គល ឬអ្នកណាម្នាក់ជាអ្នកប្រឈមមុខ ចំពោះបញ្ហានេះទេ តែនេះគឺជាបញ្ហារបស់យើងទាំងអស់គ្នា"។ ផ្ទុយពីចំនុចនេះមន្ត្រីជំនាញនៃអង្គការលីកាដូបានឱ្យដឹងថា បញ្ហានេះជាកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការទទួលខុសត្រូវ ដូច្នេះរដ្ឋាភិបាល គឺលោកមានតួនាទីសំខាន់ណាស់ក្នុងការគ្រប់គ្រងអំពីគោលការណ៍ក្នុងប្រទេសរបស់លោក។ តែការទទួលខុសត្រូវនេះមានទំហំធំធេងពេកដែលធ្វើឱ្យលោកមានការពិបាកដែរ។

យោងលើបញ្ហានេះ លោកស្រីមួរ សុខហួរ អតីតរដ្ឋមន្ត្រីនៃក្រសួងកិច្ចការនារី ក៏មានប្រសាសន៍ថា: "ការរំលោភសេពសន្ថវៈគឺជាអំពើរំលោភទៅលើសិទ្ធិជាមនុស្សរបស់ស្ត្រី"។ ...

**... ផលប៉ះពាល់ដល់សង្គម**

មន្ត្រីជំនាញមួយរូបនៃអង្គការ លីកាដូ មានប្រសាសន៍ឱ្យដឹងថា ការកើតមានឡើងនូវអំពើបែបនេះ វាធ្វើឱ្យប៉ះពាល់ដល់កុមារយ៉ាងខ្លាំង។ ក្មេងគឺជាទំពាំងស្នងឫស្សី។ តែនៅពេលទំពាំងនោះ ទើបចេញពន្លក ស្រាប់តែត្រូវក្តៅបាក់ស្រាំនោះ វាច្បាស់ជាក្រិនងាប់មិនខាន។ ដូច្នេះ ប្រសិនទង្វើនេះនៅតែកើតមានបន្ត សង្គមខ្មែរយើងនឹងមានការអន់ថយពីព្រោះវាបានប៉ះពាល់ខ្លាំងដល់សតិអារម្មណ៍របស់ក្មេងពេញមួយជីវិតគេដូចជាខ្លាចមនុស្សប្រុសរាល់រូប សូម្បីតែឪពុកបង្កើត។

លោកស្រីមួរ សុខហួរ បន្ថែមលើចំនុចនេះថា អំពើនេះគឺជាឧក្រិដ្ឋកម្ម ក្នុងបទព្រហ្មទណ្ឌ។ ដោយហេតុថា ការរំលោភនេះវាមិនមែនត្រឹមតែការរំលោភដោយពាក្យសំដី និងពុំធ្វើទៅដោយប្រយោលទេ តែអំពើនេះវាធ្វើឱ្យប៉ះពាល់ទៅដល់ការប្រើហិង្សាលើរាងកាយ និងប៉ះពាល់ទៅដល់អ្វី ដែលជាការអៀនខ្មាស់របស់ស្ត្រី កុមារ ឬអ្នកដែលមានភេទដូចគ្នា។ លោកស្រី បន្តថា សកម្មភាពទាំងនេះធ្វើឱ្យសីលធម៌នៅក្នុងប្រទេសរបស់យើងមានការធ្លាក់ចុះយ៉ាងខ្លាំង។

**វិធានការទប់ស្កាត់ និងក្តីសង្ឃឹមនាពេលអនាគត**

លោកយឹម ប៉ូ បន្ថែមថា នៅក្នុងការទប់ស្កាត់យើងឃើញថា អាជ្ញាធរមូលដ្ឋាន ឬក៏សមត្ថកិច្ចនៅពេលដែលការពារយើងធ្វើយ៉ាងណាបង្ក្រាបឱ្យបាន នៅពេលដែលមានជនល្មើសបង្កឡើង។ ពេលណាដែលយើងចាប់បាននោះ អ្នកដទៃៗទៀតមានការភ័យខ្លាច តែប្រសិនបើការរំលោភនោះនៅតែមានដដែលនៅកន្លែងតែមួយ នោះការរំលោភ នៅតែមានបន្តជានិច្ច។ ដូច្នេះ យើងគួរតែគិតគូរពីការអនុវត្តន៍ច្បាប់ និងការអប់រំដល់ប្រជាពលរដ្ឋ ឱ្យបានកាន់តែខ្លាំង។ ប្រសិនបើចំនុចសំខាន់ទាំងពីរមុខនេះ យើងអនុវត្តពុំបាននោះ បញ្ហារំលោភនេះនឹងកាន់តែមានការកើនឡើងកាន់តែខ្លាំងឡើងៗ។

“បើស្ថាប័នពាក់ព័ន្ធ ព្យាយាមអប់រំ និងផ្សព្វផ្សាយ ទៅដល់ប្រជាពលរដ្ឋ ក្មេងៗ ពិសេសនៅតាមតំបន់ដាច់ស្រយាល ឱ្យយល់ដឹងពីការការពារខ្លួន ក៏ដូចជាបញ្ហាដែលអាចកើតមានចំពោះពួកគេ ហើយការអនុវត្តន៍ច្បាប់ត្រូវបានពង្រឹងបន្ថែមនោះ បញ្ហានេះ នឹងអាចកាត់បន្ថយបាន១កម្រិត“។ នេះបើយោងតាមប្រសាសន៍របស់មន្ត្រីជំនាញនៃអង្គការលីកាដូ។

**ច្បាប់ដាក់ទោស**

ក្រមព្រហ្មទណ្ឌចាត់ទុកបទរំលោភជាបទឧក្រិដ្ឋ និងការបៀតបៀនកេរ្តិ៍ខ្មាស់ជាបទឧក្រិដ្ឋមជ្ឈិម។ មាត្រា ៣៣ ចែងថា ជនណារំលោភ ឬប៉ុងរំលោភជនម្នាក់ទៀត ទោះភេទដូច ឬមិនដូចគ្នា ត្រូវមានទោសពីបទសេពសន្ថវៈ ផ្តន្ទាទោសដាក់គុកពី៥ឆ្នាំ ទៅ១០ឆ្នាំ។ ប៉ុន្តែពុំបានចែងពីនារីក្រោមអាយុ ១៨ឆ្នាំ ឬការរួមភេទដោយស្ម័គ្រចិត្តជាមួយអនីតិជនទេ។

## លោកបូជាចារ្យ សេរ៉ាលដ៏: “បើចិត្តគំនិតយើងដាក់ទោសយើង ព្រះជាម្ចាស់ទ្រង់ឈ្វេងយល់ទាំងអស់”


Photo: M. Kunthear

ព្រះសហគមន៍កាតូលិកមិនត្រឹមតែចូលរួមចំណែកក្នុងការជួយដល់ជនក្រីក្រនៅតាមជនបទស្រុកស្រែចំការប៉ុណ្ណោះទេ តែព្រះសហគមន៍ក៏តែងចូលរួមជួយ និងយកចិត្តទុកដាក់លើបញ្ហាមួយចំនួនដែលកំពុងកើតឡើងនៅក្នុងសង្គមខ្មែរសព្វថ្ងៃនេះដែរដូចជារួមចំណែកក្នុងការផ្តល់ការអប់រំជាដើម។ លើសពីនេះទៀតបញ្ហាដែលសំខាន់គឺការចូលរួមលើកទឹកចិត្ត និងផ្តល់កន្លែងស្នាក់នៅចំពោះជនរងគ្រោះដោយសារការប្រមាថមើលងាយលើរាងកាយផងដែរ។

ជាមួយគ្នានេះ លោកបូជាចារ្យសេរ៉ាលដ៏ នៃព្រះសហគមន៍កាតូលិកក្រុងកំពង់ចាមបានមានចំណាប់អារម្មណ៍ថា អំពើរំលោភសេពសន្ថវៈគឺជាអំពើមួយអាក្រក់បំផុត ដែលធ្វើឱ្យជនរងគ្រោះមានការខ្មាស់អៀនយ៉ាងខ្លាំងរហូតអាចនាំឱ្យពួកគេមានគំនិតសម្លាប់ខ្លួន។ តាមព្រះគម្ពីរ បានចែងនូវឃ្លាមួយថា: “ប្រសិនបើចិត្តគំនិតរបស់យើងដាក់ទោសយើងនោះ ព្រះជាម្ចាស់ដែលធំជាងចិត្តរបស់យើង ទ្រង់ឈ្វេងយល់ទាំងអស់”។ ព្រះបន្ទូលបានផ្តល់នូវសេចក្តីសង្ឃឹមជាប់ជានិច្ច ព្រោះព្រះជាម្ចាស់តែងតែស្រលាញ់យើងគ្រប់ៗគ្នាទាំងអស់។ ម្នាក់ៗត្រូវយល់ថា ពួកគេគឺជាជនរងគ្រោះ តែមិនមែនបណ្តាលមកពីសេចក្តីបាបរបស់គេឡើយ ផ្ទុយមកវិញអ្នកដែលបានប្រព្រឹត្តនូវអំពើដ៏អាក្រក់នោះទេដែលជាអ្នកមានបញ្ហាចំពោះជីវិតរបស់គេនៅពេលណាមួយ ដែលតបស្នងទៅនឹងអំពើដែលពួកគេបានប្រព្រឹត្តជាមិនខាន ហើយមនុស្សប្រភេទនេះតែងតែមានសេចក្តីភ័យខ្លាចចំពោះសកម្មភាពដែលពួកគេបានធ្វើជានិច្ច។ ជនរងគ្រោះពេលខ្លះបានដាក់ទោសចំពោះខ្លួនឯងដោយគិតថា ខ្លួនឯងប្រឡាក់ប្រឡូកជាមួយនិងភាពស្មោគគ្រោក មិនបរិសុទ្ធ ជាពិសេសប្រសិនបើអំពើនេះកើតឡើងចំពោះក្មេងមិនទាន់គ្រប់អាយុ (អនីតិជន) ពួកគេនឹងទទួលរងរបួសផ្លូវចិត្តអស់មួយជីវិត និងពិបាកក្នុងការព្យាបាលទៀតផង។

ព្រះជាម្ចាស់មិនដែលដាក់ទោសចំពោះជនណាមួយឡើយ ទោះបីជននោះបានប្រព្រឹត្តទង្វើអ្វីក៏ដោយ ហើយទោះបីជាមនុស្សជាច្រើនស្អប់ខ្ពើមពួកគេខ្លាំងយ៉ាងណាក៏ដោយ។ ពួកគេនៅតែជាបុត្ររបស់ព្រះជាម្ចាស់ជានិច្ច ដូច្នេះក្នុងនាមយើងជាបូជាចារ្យ បងស្រី ឬសាច់ញាតិរបស់គេ គួររកផ្លូវណាមួយដើម្បីជួយដល់ពួកគេ ប៉ុន្តែយើងគួរប្រុងប្រយ័ត្នផងដែរ។

អត្ថបទដោយមុំ គន្ធា និងរ៉ូ បូរ៉ា





ការអប់រំចំណេះទូទៅដល់កុមារា កុមារី យុវជន យុវនារី ជាគោលដៅចម្បងមួយក្នុងចំណោមគោលដៅផ្សេងៗទៀតរបស់ព្រះសហគមន៍កាតូលិកនៅកម្ពុជាដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស បន្ថយគ្រោះពុំចេះអក្សរ និងភាពក្រីក្រ។

# អាហារូបករណ៍ ឆ្នាំ ២០០៦-២០០៧


Photo: John Baptis Center

សិស្សក្នុងមណ្ឌលយ៉ូហាន បាទីស្ត តែងបង្កើនទំនាក់ទំនងល្អជាមួយគ្នា

មណ្ឌលសន្តយ៉ូហាន បាទីស្ត គឺជាមណ្ឌលមួយសម្រាប់ទទួលសិស្សដែលកំពុងសិក្សានៅវិទ្យាល័យ។ មណ្ឌលនេះស្ថិតនៅក្រោមការគ្រប់គ្រង់នៃព្រះសហគមន៍ភូមិភាគភ្នំពេញ។

សម្រាប់ឆ្នាំសិក្សា ២០០៦-២០០៧ (តុលា-មិថុនា) ដោយមានបទពិសោធន៍ ក្នុងការជ្រើសរើសសិស្ស មកពីខេត្តនានាឱ្យទទួលអាហារូបករណ៍បន្តការសិក្សារបស់ខ្លួន នៅក្នុងក្រុងភ្នំពេញ រៀងរាល់ឆ្នាំនោះ។ នៅឆ្នាំនេះផងដែរ មណ្ឌលមានកិត្តិយស និងសូមជម្រាបជូនដំណឹងថា: ឆ្នាំនេះមណ្ឌលចាប់ផ្តើមធ្វើការជ្រើសរើសសិស្សថ្មីបន្ថែមទៀត ឱ្យចូលស្នាក់នៅក្នុងមណ្ឌល។ ការជ្រើសរើស គឺសម្រាប់តែសិស្សទាំងឡាយដែលមានកម្រិតវប្បធម៌ចាប់ពីថ្នាក់ទី១០ ឡើងដល់ថ្នាក់ ទី១២ប៉ុណ្ណោះ។ ការស្នាក់នៅក្នុងមណ្ឌលយ៉ូហាន បាទីស្ត នឹងផ្តល់ឱ្យសិស្សនូវអត្ថប្រយោជន៍ជាច្រើនខាងក្រោម:

ទី១: ការសិក្សាបន្ថែមលើមុខវិជ្ជាសំខាន់ៗ រួមមាន គណិតវិទ្យា រូបវិទ្យា ជីវវិទ្យា គីមីវិទ្យា ភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងមណ្ឌល។ ម្យ៉ាងទៀត មណ្ឌលមានសកម្មភាពជួយឱ្យសិស្សស្គាល់ខ្លួនឯង និងអ្នកដទៃ ហើយជួយឱ្យសិស្សយល់ដឹងកាន់តែច្បាស់ពីចំនុចខ្សោយ ចំនុចខ្លាំង ចំនុចល្អ និងចំនុចអាក្រក់សម្រាប់ការរស់នៅប្រចាំថ្ងៃតាមបទពិសោធន៍ខ្លួន។ ពិសេសទៀត វានឹងធ្វើឱ្យសិស្សយល់ដឹងកាន់តែច្បាស់និងស៊ីជម្រៅថែមទៀតពីរបៀបរស់នៅជាសហគមន៍។

ទី២: ការរិះគិតពិចារណារួមគ្នាអំពីសកម្មភាពផ្សេងៗ ការអធិដ្ឋាន និងអភិបូជា ទាំងនេះ នឹងធ្វើឱ្យសិស្សកាន់តែយល់ដឹង និងស្គាល់ព្រះជាម្ចាស់ បានកាន់តែច្បាស់ ព្រមទាំងមានភាពក្លាហាននៅក្នុងជីវិតរស់នៅរបស់ខ្លួន។

ទី៣: មានដំណើរកំសាន្តជាដើម។

ដូច្នេះបើសិនជាបេក្ខជនណា មានចំណាប់អារម្មណ៍ ចង់ចូលរួមស្នាក់នៅរួមរស់ជាសហគមន៍ នៅក្នុងមណ្ឌលសន្តយ៉ូហាន បាទីស្ត សូមបំពេញនូវលក្ខន្តិកៈដូចខាងក្រោម:

បេក្ខជន គួរទាក់ទងជាមួយលោកបូជាចារ្យដែលទទួលខុសត្រូវតាមព្រះសហគមន៍ខ្លួន ក្នុងការចង់ដឹងពីព័ត៌មានបន្ថែមផ្សេងៗទៀត ដូចជា ការបំពេញសំណុំបែបបទជាដើម។

រាល់ឯកសារ ឬសំណុំបែបបទផ្សេងៗ ត្រូវតែបំពេញដោយសាមីបេក្ខជនខ្លួនឯងផ្ទាល់។

ពេលមកកាន់មណ្ឌល បេក្ខជនត្រូវភ្ជាប់មកជាមួយ នូវរាល់ឯកសារផ្សេងៗ ដូចជា: សំណុំបែបបទដែលបានបំពេញរួច រូបថតថ្មី ១សន្លឹក (៤ x ៦) សៀវភៅពិន្ទុប្រចាំឆ្នាំ សៀវភៅតាមដាន ព្រមទាំងសៀវភៅសិក្ខាគារិក (ចាប់ពីថ្នាក់ទី៧ រហូតដល់ថ្នាក់ដែលបេក្ខជនកំពុងសិក្សា)។

បេក្ខជន នឹងត្រូវជួបសម្ភាសន៍ ជាមួយអ្នកទទួលខុសត្រូវមណ្ឌលនៅថ្ងៃដែលបេក្ខជនយកពាក្យមកដាក់។

ចំពោះលទ្ធផល ពេលក្រោយយើងនឹងជូនដំណឹង តាមរយៈបូជាចារ្យ ដែលទទួលខុសត្រូវនៅឯព្រះសហគមន៍របស់អ្នក នៅថ្ងៃទី២១ សីហា ឆ្នាំ២០០៦។

បេក្ខជនគ្រប់រូប ត្រូវនៅលីវ និងមានកម្រិតវប្បធម៌ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ ។

មណ្ឌលយើងរើសតែបេក្ខជនជាសិស្សប្រុសប៉ុណ្ណោះ។

បេក្ខជនគ្រប់ៗរូប អាចមានសិទ្ធិដាក់ពាក្យបាន មិនប្រកាន់ថាជាគ្រីស្តបរិស័ទ ឬពុទ្ធបរិស័ទឡើយ។

បេក្ខជនត្រូវមកធ្វើការសម្ភាសន៍នៅមណ្ឌល ថ្ងៃទី២៧-២៨ កក្កដា ឆ្នាំ២០០៦ ពីម៉ោង ៨:០០ ដល់១១:០០ ព្រឹក។

មណ្ឌលសន្តយ៉ូហាន បាទីស្ត

**ទំនាក់ទំនងទៅកាន់មណ្ឌល**

សម្រាប់ព័ត៌មានបន្ថែមផ្សេងៗទៀតនោះ សូមបេក្ខជនធ្វើការទំនាក់ទំនងជាមួយនិងអ្នកស្រីម៉ារីឡូ ជូលី និងលោករ៉េនេអាយ៉ាឡា តាមរយៈអាសយដ្ឋានផ្ទះលេខ ២២ ផ្លូវលេខ ៥៤២ សង្កាត់បឹងកក់១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ: ០១២ ៣៧៤១០២។ មួយវិញទៀត បេក្ខជនអាចធ្វើការទំនាក់ទំនងទៅកាន់លោកបូជាចារ្យប្រ៊ុយ ណូ តាមរយៈទូរស័ព្ទលេខ: ០១៦ ៨៣១ ៦៨៣។

សូមព្រះជាម្ចាស់គង់នៅជាមួយបងប្អូន និងសូមឱ្យបងប្អូនទទួលបានតែជោគជ័យនៅក្នុងជីវិត!

# ទំនាក់ទំនងល្អ តើវាអាស្រ័យលើកត្តាអ្វីខ្លះ?

មនុស្សប្រុស ឬស្រី នៅពេលដែលពុំចេះទំនាក់ទំនងជាមួយអ្នកដទៃ វាអាចធ្វើឱ្យមានផលវិបាកចំពោះខ្លួនឯងក្នុងពេលណាមួយជាមិនខាន។ តើយើងត្រូវធ្វើយ៉ាងណាដើម្បីឱ្យមានភាពជោគជ័យក្នុងការធ្វើទំនាក់ទំនងពីខ្លួនយើងទៅកាន់អ្នកដទៃ ?



Photo: S. Metrey

រូបលំអ : មិត្តភាពមួយដែលល្អប្រពៃត្រូវការនូវការស្វែងយល់ និងជួយដល់គ្នាទៅវិញទៅមក

**តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យមានទំនាក់ទំនងល្អរវាងអ្នកនៅជុំវិញខ្លួន ?**

រ៉ានីមិនសូវចូលចិត្តនិយាយជាមួយអ្នកនៅជុំវិញនាង ព្រោះនាងគិតថានាងអន់ជាងគេ។ នាងចូលចិត្តនៅម្នាក់ឯងដោយនាងមានអារម្មណ៍ធុញទ្រាន់។ ក្នុងរយៈពេល២ឆ្នាំដែលនាងរៀនចប់ គឺនាងពុំមានមិត្តភ័ក្តិឡើយ។ នាងមានការតូចចិត្តចំពោះខ្លួនឯង ដែលមានចរិតដូចនេះ នាងចង់កែចរិតរបស់នាងដោយអាចចេះនិយាយលេងសើចជាមួយអ្នកនៅជុំវិញខ្លួននាង តែនាងមិនអាចធ្វើបានទេ។

**សាស្ត្រាចារ្យ ផាន់ ចាន់ពៅ :** ចំនុចសំខាន់ របស់រ៉ានី គឺត្រូវបង្កើតមិត្តឱ្យបានច្រើន ទី១ មិត្តដែលខ្លួនស្រលាញ់ មិត្តដែលខ្លួនទុកចិត្តជាងគេ តែនៅពេលនេះរ៉ានីមិនទាន់មាននៅឡើយ។ នៅត្រង់នេះរ៉ានីត្រូវបញ្ឈប់ជាបន្ទាន់ នូវការគិតថាខ្លួនឯងអន់ជាងគេ។ ចំនុចដែលគិតអំពីភាពអវិជ្ជមានចំពោះខ្លួនឯង គឺជាចំនុចមួយដែលមានគ្រោះថ្នាក់ ជាការដឹកនាំទៅរកភាពបរាជ័យសម្រាប់ខ្លួន។ ដូច្នេះយើងត្រូវព្យាយាមចូលរួមនៅក្នុងចំណោមមិត្តភ័ក្តិ ប៉ុន្តែត្រូវបញ្ឈប់ជាបន្ទាន់នូវអ្វីៗដែលយើងបានបន្ទោសខ្លួនឯង។

**តើទំនាក់ទំនងរបស់ខ្ញុំទាល់តែមានលុយឬ ?**

ដារ៉ូ មកពីខេត្ត ជាកូនកសិករ លោកពុំហ៊ានរាប់អានជាមួយមិត្តភ័ក្តិ ពីព្រោះលោកគិតថា អ្នកដែលរស់នៅទីក្រុងសុទ្ធជាអ្នកមានលុយ ដូច្នេះប្រសិនលោកដើរលេងជាមួយគេ លោកត្រូវការចំណាយលុយច្រើន។ អ្វីដែលសំខាន់នោះ គឺលោកគិតថា លោកអន់ជាងគេនោះគឺការគ្មានលុយ។

**លោកបូជាចារ្យ សេរ៉ាលដ៏ :** ចរិកាអាចនាំបញ្ហាដល់ការទំនាក់ទំនងដែរ។ យើងត្រូវគិតថា ទំនាក់ទំនងរវាងមនុស្សនិងមនុស្សមានលក្ខណៈស្មុគស្មាញបន្តិចដែរ ជួនកាលទំនាក់ទំនងក៏អាស្រ័យលើលុយ និងជួនកាលយោងលើការចេះធ្វើទំនាក់ទំនងដោយខ្លួនឯងតែម្តង ថាតើ ការទំនាក់ទំនងនោះមានលក្ខណៈល្អយ៉ាងណា ? ។ ដារ៉ូត្រូវគិតថា ខ្លួនជាមនុស្សល្អ មានគុណសម្បត្តិច្រើន។ ទំនាក់ទំនងមិនមែនកើតឡើងដោយសារតែលុយទេ វាកើតឡើងដោយសេចក្តីស្រលាញ់។ លុយអាចនាំទុក្ខលំបាកជាជាងសុភមង្គល។ អ្វីដែលដារ៉ូមានទំនាក់ទំនងសព្វថ្ងៃគឺជាទំនាក់ទំនង ដែលមានប្រភពចេញពីក្តីស្រលាញ់ មិនមែនមកពីលុយទេ។

**ធ្វើយ៉ាងណាដើម្បីឱ្យគេយល់ចិត្ត?**

ស្រីធាច្រើនមានសំដីគំរោះគំរើយ។ មានមនុស្សជាច្រើនមិនពេញចិត្ត។ ចំនុចអាក្រក់មួយគឺថានាងពុំចូលចិត្តអ្នកនិយាយគំរោះគំរើយដាក់នាង ប៉ុន្តែនាងចូលចិត្តនិយាយគំរោះគំរើយនឹងគេ។ នាងចង់ឱ្យគេយកចិត្តទុកដាក់នឹងនាងឱ្យច្រើន។

**សាស្ត្រាចារ្យ ផាន់ ចាន់ពៅ :** ក្នុងខ្លួនរបស់មនុស្សមានរចនាសម្ព័ន្ធលក្ខណៈ៤យ៉ាង គឺទម្រង់ សម្បទាន ឬកពារ និងអត្តចរិត។ បើសិនយើងចង់ឱ្យគេស្រលាញ់ច្រើន គួរតែយើងស្រលាញ់គេឱ្យអស់ពីចិត្តយើងផងដែរ។ យើងប្រាថ្នាសេចក្តីស្រលាញ់ពីគេ តែបែរជាយើងបង្កើតការឈឺចាប់ទៅដល់គេនោះប្រហែលជាគ្មានលទ្ធផលល្អទេ។ ចំពោះស្រីធា នាងគួរតែប្តូរអត្តចរិតរបស់នាង នោះនាងនឹងទទួលបានសេចក្តីសុខសុភមង្គល និងការរាប់អានពីអ្នកនៅជុំវិញខ្លួននាង។

មុំ គន្ធា

### មិត្តភាពយូរអង្វែង

“មិត្តភាព” ដែលពិតប្រាកដមិនមែនកើតឡើងដោយសារមាសប្រាក់ ឬឋានៈឡើយ។ ចំណងមិត្តភាពយូរអង្វែងប្រៀបបីដូចជា ទ្រព្យសម្បត្តិដ៏មហាសាលមិនអាចកាត់ថ្លៃបាន ដែលមនុស្សមួយចំនួនគ្មាន។ ពិតណាស់ ! មិត្តភាពតែងរំលេចឡើងចំពោះមនុស្សគ្រប់រូប ប្រសិនគេព្រមទទួលយកដោយសេចក្តីស្រលាញ់ និងដោយការគោរពចំពោះដៃគូរបស់ខ្លួន។ ទ្រព្យសម្បត្តិមិនអាចធ្វើឱ្យចំណងមិត្តភាពស្ថិតស្ថេរយូរអង្វែងបានទេ។





# ការពារដង្កូវបំផ្លាញស្រូវ

សម្រាប់ប្រជាជនខ្មែរ ស្រូវជាដំណាំអាហារជាមូលដ្ឋានបរិភោគប្រចាំថ្ងៃ។ ការបង្កើនផលស្រូវគឺជាកង្វល់ចម្បងរបស់ប្រជាកសិករ។ ប៉ុន្តែបញ្ហាដែលពួកគាត់តែងជួបប្រទះនៅពេលដាំដុះដំណាំស្រូវ គឺស្រូវត្រូវទទួលការយាយីពីដង្កូវ និងសត្វល្អិតចង្រៃ។ តើមានវិធីណាខ្លះដើម្បីកាត់បន្ថយការបំផ្លាញទាំងនេះ ?



Photo: P. Samphy

លោកគាម មករាឌី ប្រធានកម្មវិធី និងជាអ្នកស្រាវជ្រាវ បច្ចេកទេស នៃអង្គការ សេដាក

ចាប់ពីដំណាក់ការសាបព្រោះដកស្ទូង រហូតដល់ការប្រមូលផល ដំណាំស្រូវ វាមានសត្រូវសំខាន់ៗនៅតាមវគ្គនីមួយៗ។ តួយ៉ាងនៅវគ្គសំណាប អាចច្រើនមានពួកដង្កូវកាត់ស្លឹក និងមមាចត្នោតបំផ្លិចបំផ្លាញ។ ពួកមមាចត្នោតស៊ីជញ្ជក់រុក្ខរសរបស់ស្រូវ ដែលធ្វើឱ្យស្រូវទៅជាតឿមិនអាចឱ្យផល។ ដល់នៅវគ្គលូតលាស់ អាចលេចចេញពពួកដង្កូវស៊ីរូងដើម ដែលអាចស៊ីបណ្តូលស្រូវ។ លុះដល់វគ្គផលិតកម្ម ហៅថា វគ្គដាក់ទឹកដោះ វាក៏អាចកើតមានពពួកសត្វស្រឹង ដែលជញ្ជក់យកទឹកដោះរបស់ស្រូវដែលធ្វើឱ្យស្រូវមិនអាចឱ្យផលល្អ។

តាមប្រសាសន៍របស់លោកគាម មករាឌី ប្រធានកម្មវិធី នៃអង្គការសេដាក បានឱ្យដឹងថា ដើម្បីកាត់បន្ថយសត្វល្អិត ឬដង្កូវកុំឱ្យបំផ្លាញស្រូវ យើងមានវិធីសាស្ត្រដូចជា :

ទីមួយគឺការជ្រើសរើសពូជ។ យើងត្រូវជ្រើសរើសពូជ ដែលមានសុខភាពល្អ ពោលគឺល្អតាំងពីមេបាវា ដូចជា ស្រែមេបាវាមិនមានមមាចត្នោតស៊ីជាដើម។ ទីពីរគឺជាការរៀបចំស្រែ យើងត្រូវភ្ជួររាស់ឱ្យបានល្អ ឱ្យបានពីរ-បីសា រួចត្រូវហាលដីឱ្យបានស្ងួតល្អ។ ការភ្ជួររាស់នេះអាចសម្លាប់ពងដង្កូវ ឬសត្វល្អិតដែលមាននៅក្នុងដី។ ម្យ៉ាងទៀតនោះយើងត្រូវស្ទូងតែសំណាបណាដែលមានដើមថ្លោសធំលូតលាស់ល្អ។ កាលណាវាមានសុខភាពល្អ គឺវាអាចឈ្នះជំងឺ ពោលគឺប្រសិនបើមានសត្វល្អិតអ្វីបំផ្លាញបន្តិចបន្តួច វាក៏នៅតែអាចលូតលាស់បានលឿន។ ហើយការស្ទូងនោះទៀតសោត ត្រូវទុកចន្លោះគុម្ពឱ្យបានសមស្រប ដែលអាចឱ្យពន្លឺ ឬខ្យល់ចេញចូលបានល្អ។ នេះអាចធ្វើឱ្យមិនមានជម្រកសត្វល្អិតចង្រៃ។

លើសពីនេះ លោកគាម មករា ឌី បានសង្កត់ធ្ងន់ថា ការប្រើប្រាស់ថ្នាំពុលគីមីទៅលើស្រូវ គឺមិនបានផលអ្វីទេ ពីព្រោះថាតាមធម្មតា នៅក្នុងបរិស្ថានវាលស្រែ វាតែងមានតុល្យភាពគ្នា តែងមានសត្វល្អិតដង្កូវបំផ្លាញ ហើយក៏មានពួកសត្វមានប្រយោជន៍ ដែលស៊ីសត្វចង្រៃអស់ទាំងនោះដែរ។ នៅពេលយើងប្រើប្រាស់ថ្នាំពុល វាធ្វើឱ្យសត្វមានប្រយោជន៍ ដែលចាំស៊ីសត្វចង្រៃ ដូចជា ត្រី កង្កែប ពីងពាង ឬកន្ធ្លុំយ ងាប់មុនលែងអាចស៊ីសត្វចង្រៃបាន ព្រោះពពួកសត្វមានប្រយោជន៍ទាំងនេះមិនសំងំនៅក្នុងដី ឬក្នុងដើមដូចជាពួកសត្វល្អិតដង្កូវចង្រៃនោះទេ។

ជំនួសឱ្យការប្រើថ្នាំពុលគីមី ប្រជាកសិករអាចប្រើវិធានការការពារបែបធម្មជាតិ។ ពួកគាត់អាចដកពិសោធន៍ខ្លួន ឬទៅរៀនពីអ្នកជំនាញ ខាងកសិកម្ម។ លោកគាម មករាឌី លើកឡើងថា វិធីការពារតាមបែបធម្មជាតិមានច្រើនបែបណាស់ តួយ៉ាង ដូចជា ការប្រើប្រាស់ដោយយកគ្រាប់ស្តៅ ឬមួយក៏ស្លឹកស្តៅទៅបុក បន្ទាប់មកទើបយកទឹកស្តៅទៅច្របល់ត្រាំជាមួយគ្រាប់ពូជ សំណាប ដែលបានមកពីគ្រាប់ពូជទាំងនេះភាគច្រើនមានសុខភាពល្អ ហើយសត្វល្អិតដង្កូវចង្រៃ ក៏មិនស៊ី ដោយសារវាល្វីង។ នេះគឺជាវិធីព្យាបាលបង្ការមុន។

ផាត សំភី

### កន្លែងសិក្សា

ប្រសិនបើលោកអ្នកចង់សិក្សាអំពីរបៀប ឬបច្ចេកទេសនៃការដាំដំណាំគ្រប់ប្រភេទគឺមាននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) ឬអាចអញ្ជើញបុគ្គលិករបស់សេដាកទៅបង្រៀនដល់ទីកន្លែងតែម្តងដោយគិតតម្លៃសមរម្យ។ ទំនាក់ទំនងទូរស័ព្ទ : ០១២ ៣២៥៧១០។



Photo: P. Samphy

ប្រជាកសិករអាចបង្កើនទិន្នផលដោយការជ្រើសរើសពូជល្អ និងធ្វើតាមបច្ចេកទេស

## ដំរីនីមួយៗមានប្រមោយតភ្ជាប់ទៅនឹងវត្ថុមួយ សូមប្រិយមិត្តសាកល្បងស្វែងរកទៅមើលថា តើដំរីមួយណាយកប្រមោយទៅចាប់វត្ថុមួយណា?





# ធ្វើជាងទង

**នៅពេលយើងមានលោហៈធាតុមានតម្លៃ ដូចជា មាស ប្រាក់ សំរិទ្ធ លង្ហិន-ល- យើងតែងចង់យកពួកវាធ្វើជាគ្រឿងលំអនៅលើរាងកាយ។ ជាងទងគឺជាអ្នកជំនាញកែច្នៃរបស់អស់ទាំងនេះ។**



Photo: P. Samphy

នេះគឺជាការងារដែលត្រូវអង្គុយធ្វើពេញមួយថ្ងៃដោយភាពអត់ធ្មត់

តាមប្រសាសន៏របស់លោកអេង ពៅ ជាជាងទងឯកទេសដាំត្បូងនៅនឹងគេហដ្ឋានមួយស្ថិតនៅខាងក្រោយរដ្ឋសភាជាតិបានឱ្យដឹងថា ការងាររបស់ជាងទងមានច្រើនណាស់ វាគឺជាការងារកែច្នៃលើលោហៈធាតុមានតម្លៃ ដូចជាមាស ដើម្បីធ្វើជាគ្រឿងតុបតែងលំអគេហដ្ឋាន ឬក៏គ្រឿងអលង្ការលំអកាយ មានដូចជា ចិញ្ចៀន ខ្សែដៃ ខ្សែក បណ្តោងខ្សែក ឬក៏ក្រវិល-ល-។ គ្រឿងអលង្ការអស់ទាំងនេះ ជួនកាលក៏ត្រូវមានដាំត្បូង ឬពេជ្រស្អាតៗ ជាប់ជាមួយផង។

ដើម្បីបំពេញចិត្តអតិថិជនបាន ជាងទងត្រូវតែខិតខំធ្វើយ៉ាងណាដើម្បីឱ្យគ្រឿងអលង្ការ ដែលធ្វើមានគុណភាពល្អ ធានាការប្រើប្រាស់បានយូរ មិនបាត់តម្លៃ (បើមាសកុំឱ្យបាត់ទឹក) ជាពិសេសនោះគឺត្រូវមានន្ធូវសោភ័ណភាព ភាពស្រស់ស្អាតប្រកបដោយភាពទាក់ទាញផងដែរ។ នេះជាការងារលំបាកមួយដោយត្រូវការនូវភាពអត់ធ្មត់ពីព្រោះវាទាមទារនូវការធ្វើជាដំណាក់ៗ ទំរាំគ្រឿងអលង្ការមួយបានសំរេច។ តួយ៉ាងដូចជាការធ្វើខ្សែដៃមាសមួយ ដំបូងត្រូវយកមាសមកបញ្ចុះទឹកតាម ដែលអតិថិជនត្រូវការ រួចហើយ ត្រូវយកទៅកិន ឬផែទ្រង់ទ្រាយ រួចមកគឺដំណាក់កាលច្នៃម៉ូដដោយធ្វើឡើងដោយការផ្សារ ការដំ និងការឆ្លាក់ក្បាច់ជាដើម បើមានការដាំពេជ្រ-ត្បូង ត្រូវធ្វើនៅដំណាក់កាលបន្ទាប់។ ចុងក្រោយគឺការដុសខាត់ឱ្យភ្លឺរលោង និងមានសោភ័ណភាព។

តាមធម្មតា ធ្វើជាងទងពូកែម្នាក់ ទាល់តែអ្នកនោះមានដុងពីកំណើត ប៉ុន្តែលោកអេង ពៅ ពន្យល់ថា គេពុំអាចក្លាយជាជាងពូកែបានទេ បើគេធ្វើការងារដោយមិនពិនិត្យ មិនសំរិតសំរាំង និងគ្មានភាពប្រឹងប្រែង ធ្វើការឱ្យតែរួចពីដៃនោះ។

តាមពិតនៅនឹងកន្លែងមួយ ជាងទងមានឯកទេសខុសៗ គ្នាដូចជា អ្នកខ្លះជំនាញខាងដាប់មាស អ្នកខ្លះខាងធ្វើខ្សែ អ្នកខ្លះខាងដាំត្បូង និងខ្លះជំនាញខាងឆ្លាក់ក្បាច់-ល-។ ម្នាក់ៗអាចធ្វើលើជំនាញដទៃទៀតបានគ្រាន់តែមិនសូវស្ទាត់។

លោកអេង ពៅ ប្រាប់ថា សម្រាប់ចំនួលរបស់ជាងទង គឺកូនជាងចែកភាគរយកម្រៃជាមួយមេជាង តាមការព្រមព្រៀងគ្នា ដូចជាកន្លែងលោក បើធ្វើគ្រឿងអលង្ការមួយ មានតម្លៃ ១០ កូនជាងបាន ៥០% និងមេជាងបាន ៥០%។

ផាត សំភី

### តើត្រូវចាប់ផ្តើមយ៉ាងណា?

ដើម្បីក្លាយជាជាងទង យើងអាចទៅរៀនជំនាញនេះនៅផ្ទះ ដែលគេបើករបរនេះតែម្តង បើសិនអ្នកគ្រប់គ្រងយល់ព្រម នោះយើងអាចចេះជំនាញនេះពីជាងមុនៗ ប្រាប់តៗគ្នា និងពីមេជាងដែលបង្ហាញយើង។ បើចង់រៀនពូកែ យើងត្រូវតស៊ូព្យាយាម យកចិត្តទុកដាក់ គឺរៀនសួរ រៀនធ្វើ និងទទួលខុសត្រូវចំពោះការងារដែលយើងបានធ្វើនោះ។

## សុខភាព

# មហារីកសុដន

**ដើមទ្រូងជាសោភ័ណភាពនៃសម្រស់មួយសម្រាប់នារីគ្រប់ៗរូប។ ការថែរក្សាសុដនកុំឱ្យកើតមាននូវជំងឺមហារីកគឺជាប្រការចាំបាច់បំផុតរបស់ស្ត្រី។ តើត្រូវស្វែងយល់ និងការពារយ៉ាងណា?**

សព្វថ្ងៃនេះ មហារីកសុដនជាជំងឺមួយ ដែលឈរលំដាប់ថ្នាក់ទី២បន្ទាប់ពីជំងឺមហារីកមាត់ស្បូន។ ស្ត្រីៗភាគច្រើន ចាប់ពីអាយុ៤០ឆ្នាំឡើង គឺមានលទ្ធភាពកើតជំងឺនេះច្រើនជាងស្ត្រីវ័យក្មេង។ លោកវេជ្ជបណ្ឌិតតន់ ផល្លី អនុប្រធានមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត និងជាអ្នកទទួលបន្ទុកជំងឺមហារីក ជំនាញវះកាត់មហារីកសុដន បានឱ្យដឹងថា ដំណើរការដំបូងនៃមហារីកដោះកើតលើស្ត្រី ដែលភាគច្រើន មិនបានដឹងជាមុន។ វាស្ថិតនៅក្នុងខ្លួនយើង រយៈពេល៤-១០ឆ្នាំ ដែលជាកោសិកាតូចមើលមិនឃើញ បន្ទាប់មកទើបកើតបន្តិចម្តងៗជាកោសិកាមួយមិនធម្មតា។ ក្រោយមកទៀត ក៏កើតចេញជាដុំមហារីក ដោយដំបូងកើតជាដុំតូច ដែលយើងស្ទាប មិនអាចប៉ះទេ។ បន្ទាប់មកវារីវដ្តទៅជាដុំធំបន្តិចម្តងៗ និងមានសភាពរឹងនៅជាប់នឹងដោះ។ លោកបន្តថា អ្នកជំងឺអាចដឹងថាកើតជំងឺនេះ ដោយឃើញមានអាការៈឈឺ នៅពេលដុំរឹងនោះកើតជាខ្ទុះជិតបែក និងឈឺចុកចាប់ជុំវិញដោះ កើតមានកូនកណ្តុរនៅក្លៀក ជួនមានឈាមចេញតាមរន្ធដោះផង។

លោកបន្តថា មូលហេតុចំបងនៅទូទាំងពិភពលោក មិនទាន់ដឹងច្បាស់ថា ជំងឺនេះបណ្តាលមកពីអ្វីនៅឡើយ។ ប៉ុន្តែយើងសង្កេតឃើញថាមានកត្តាជាច្រើនដែលផ្គួបផ្សំគ្នា ដែលអាចបង្កើតជាជំងឺនេះដូចជា ទី១ បណ្តាលមកពីហ្សែន ទី២ មកពីចំណីអាហារ (មិនអាចកំណត់ថាចំណីបែបណាៗទេ) និងទី៣មកពីវិទ្យុសកម្ម។ យើងនៅមិនទាន់មាននូវវិធានការណាមួយដើម្បីការពារជំងឺនេះទេ ក្រៅពីត្រូវពិនិត្យខ្លួនឯង ដូចជាស្ទាបនៅបរិវេណដោះ បើមានប៉ះដុំរឹងស្អិតជាប់នឹងស្បែកដោះ គួរទៅពិគ្រោះជាមួយពេទ្យជំនាញជាបន្ទាន់។

ការបូមដោះ ឬបណ្តឹងដោះមិនធ្វើឱ្យក្លាយជាមហារីកទេ តែមិនដឹងថាវានឹងអាចកើត ឬយ៉ាងណានាពេលអនាគត។

មុំ គន្ធា និងហ៊ូ សុខធារី



Photo: M. Kunthear

លោកវេជ្ជបណ្ឌិតតន់ ផល្លី មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

### អំពីដុំមហារីក

ចែកចេញជា ៤កំរិត កំរិតទី១ ដុំមានទំហំក្រោម២ស.ម (អាចដឹងថាមានជំងឺ) កំរិតទី២ ទំហំពី២-៥ស.ម កំរិតទី៣ លើសពី៥ស.ម និងកំរិតទី៤ ដុំនោះមកជាប់នឹងស្បែកសាច់ទ្រូង។

# លោកអភិបាលគីកេ: “ខ្ញុំគិតថាព្រះជាម្ចាស់រស់នៅជាមួយបងប្អូន”



លោកគីកេ ហ្វីការេដូ អភិបាលភូមិភាគបាត់ដំបង

Photo: L. Sovanna

**លោកអភិបាលគីកេ ហ្វីការេដូ បានក្លាយជាបូជាចារ្យនាថ្ងៃទី៤ កក្កដា ឆ្នាំ ១៩៩២ និងត្រូវបានតែងតាំងជាអភិបាលនៅថ្ងៃទី០២ កក្កដា ឆ្នាំ២០០០។**

---

“ខ្ញុំមិនចេះប្រកាស ដំណឹងល្អ តាមរយៈព្រះគម្ពីរទេ។ ព្រះជាម្ចាស់ប្រទានព្រះអំណោយទាន ដល់ខ្ញុំដោយឱ្យមានទំនាក់ទំនងស្រួល ជាមួយ អ្នកក្រីក្រ ដែលខ្ញុំទទួលបានច្រើនជាងប្រកាសតាមបបូរមាត់”។ នេះគឺជាសំដីម៉ឺងម៉ាត់នៃលោកអភិបាលគីកេ ហ្វីការេដូ នៃភូមិភាគបាត់ដំបង។ លោកជាជនជាតិអេស្ប៉ាញ មានរាងកាយរឹងមាំ និងស្មារតីវាងវៃ ហើយជាពិសេសគឺលោកតែងតែមមាញឹកយ៉ាងខ្លាំងក្នុងការចុះជួយដល់ជនក្រីក្រ។

ស្ថិតនៅនិងផ្ទះអង្គការ សហជីវិនព្រះយេស៊ូ ហៅកាត់ថា JRS លោកអភិបាល ក្នុងវ័យ៤៧ឆ្នាំថ្លាយបានបន្តដោយទឹកមុខស្រស់ញញឹមថា តំណែងជាអភិបាលភូមិភាគបាត់ដំបងនេះត្រូវបានគេជ្រើសរើសដោយសាររូបលោកជាសមាជិក ក្រុមសហជីវិនព្រះយេស៊ូ និងបានធ្វើការក្នុងភូមិភាគបាត់ដំបងនេះ ហើយលោកក៏មានបទពិសោធន៍ច្រើនជាមួយបងប្អូនខ្មែរនៅទីនេះផងដែរ។

លោកអភិបាលសារភាពថា: “ការធ្វើជាអភិបាល ខ្ញុំមានអារម្មណ៍ថា ជាការងារធំពេក។ ខ្ញុំយំដែលបែកចេញពីបន្ទាយព្រាប ជាកន្លែងបណ្តុះបណ្តាលជនពិការ”។ លោកបន្តដោយស្រងូតស្រងាត់ ថាបងប្អូននៅបាត់ដំបងក៏ស្រឡាញ់លោក ដូចគ្នា ពីព្រោះពួកគេជួយរូបលោក និងក្រុមក្មេងៗ ដែលមានឈ្មោះថាក្រុមជំរាបសួរ ដែលពួកគេតែងមកលេង និងច្រៀងជាមួយលោករាល់ថ្ងៃ និងគ្រីស្តបរិស័ទព្រមទាំងលោកបូជាចារ្យផងដែរ។

”ខ្ញុំគិតថា ខ្ញុំមានព្រះអំណោយទានពីព្រះជាម្ចាស់ដែលអាចឱ្យ ខ្ញុំបម្រើព្រះសហគមន៍ ដោយមានរបៀបនៅក្នុងការរៀបចំការងារ ដោយបើកចំហសម្រាប់ឱ្យក្រុមផ្សេងអាចចូលរួម ជាមួយគ្នាបានជាពិសេសខ្ញុំបានទទួលនូវការអប់រំពីក្រុមគ្រួសារសហជីវិនព្រះយេស៊ូ”។ លោកអភិបាលដែលមានកែវភ្នែកពណ៌ខៀវបន្តសំដី ដោយក្តីមុះមុត ដែលបេសកកម្មរបស់លោក គឺទាក់ទងនិងបញ្ហាសង្គមច្រើន។ នៅគ្រប់កន្លែង ដែលលោកអភិបាលកាន់កាប់គឺត្រូវមានក្រុមរបាំ ពីព្រោះលោកស្រឡាញ់វប្បធម៌ខ្មែរ ដែលមានភាពទន់ភ្លន់ តាំងពីការដើរឈរអង្គុយ ជាពិសេសគឺការសំពះ។

លោកអភិបាលបានបង្ហាញថា អ្វីដែលលោកចាប់អារម្មណ៍ គឺព្រះសហគមន៍នៅលើទឹក ដោយសារជីវភាពក្រីក្រ ពួកគេពុំសូវចាប់អារម្មណ៍ពីជំនឿដូច្នេះគាត់បានត្រឹមតែជួយដល់កូនៗពួកគេ ដើម្បីឱ្យអាចចូលសង្គមខ្មែរដោយការផ្តល់ការអប់រំ។

ក្នុងដៃកាន់រូបថតបង្កប់ដោយស្នាមញញឹម លោកអភិបាល បង្ហាញរូបភាពក្រុមគ្រួសាររបស់លោកដោយពោលថា: “ខ្ញុំជាកូនទី៧ ក្នុងចំណោមបងប្អូន៨នាក់។ ការដែលខ្ញុំក្លាយជាបូជាចារ្យនោះ គឺដោយសារតែឪពុករបស់ខ្ញុំ តែងនាំរូបខ្ញុំឱ្យធ្វើការអធិដ្ឋានជាមួយរូបគាត់ជានិច្ចកាល”។

ហ៊ួ សុខធារី

## ព្រឹត្តិការណ៍នឹងមាន!

- ថ្ងៃ១ មិថុនា: ទិវាកុមារអន្តរជាតិធ្វើឡើងនៅតាមសាលារៀនក្នុងព្រះសហគមន៍ស្ទួង កអណ្តើក ស្វាយរៀង និងព្រៃវែង នៃភូមិភាគកំពង់ចាម មានកុមារចូលរួមប្រមាណជាង ៤០០នាក់។
- ថ្ងៃ០៤ មិថុនា: មានគ្រីស្តបរិស័ទចំនួន ៥០នាក់ ទទួលអគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍ផ្សារតូច ម៉ោង ៨ព្រឹក។
- ថ្ងៃ០៤-០៥ មិថុនា: ទិវាកុមារអន្តរជាតិ ធ្វើនៅព្រះសហគមន៍ក្តុលលើ កោះរកា និងក្រចេះ ភូមិភាគកំពង់ចាម មានកុមារចូលរួមប្រមាណ ៥៥០នាក់។
- ថ្ងៃ១៨ មិថុនា: កុមារ ៣៣នាក់ ទទួលព្រះកាយលើកដំបូងនៅព្រះសហគមន៍ផ្សារតូច និង៩នាក់ នៅព្រះសហគមន៍ទួលតាំង ភូមិភាគភ្នំពេញ។
- ថ្ងៃ១៨-១៩ មិថុនា: សន្និបាតគណៈកម្មការយុវជន ភូមិភាគកំពង់ចាម រិះគិតអំពីរបៀបណែនាំអប់រំយុវជន និងឱ្យស្គាល់ពីប្រវត្តិព្រះសហគមន៍នៅលង្វែក។
- ថ្ងៃ១៩-២៥ មិថុនា: ការធ្វើទស្សនកិច្ចរបស់យុវជនជនជាតិកូរ៉េ មកពីប្រទេសសិង្ហបុរីចំនួន ២០នាក់ នៅព្រះសហគមន៍ស្ទួង ដើម្បីឱ្យស្គាល់ជីវភាពរស់នៅរបស់ប្រជាជន និងជួយជួសជុលដំបូលផ្ទះ និងជញ្ជាំងរបស់ជនក្រីក្រផងដែរ។
- ថ្ងៃ២៩ មិថុនា: សម្ពោធព្រះវិហារព្រះសហគមន៍កំពង់ឆ្នាំង។
- ក្នុងចុងខែមិថុនានេះផងដែរ: ព្រះវិហារកាតូលិកកំពង់សោមនឹងធ្វើការជួសជុលរួចរាល់ និងបើកឱ្យប្រើប្រាស់ជាថ្មី។
- ក្នុងអំឡុងឆ្នាំ២០០៦នេះ: ព្រះវិហារនៅដាក់ដាំ ខេត្តមណ្ឌលគិរី ភូមិភាគកំពង់ចាម នឹងរៀបចំធ្វើការសាងសង់។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេសម្ស អគ្គនាយក: លោកបូជាចារ្យ ហៃរណាន់ ពីនីយ៉ា